# ការសំភាសន៍របស់អ្នកមីង សើម មាស

**កៈ អ្នកដែលសំភាសន៍ ញ៉ែម លាភី** **ខៈ អ្នកដែលត្រូវគេសំភាសន៍ សើម មាស**

## ការសង្ខេបរបស់អ្នកមីង សើម មាស

អ្នកមីងសើម មាស គាត់ជាស្រ្តីម្នាក់ដែលតស៊ូខ្លាំងបំផុតនៅក្នុងជីវិត ហើយគាត់បានចិញ្ចឹមកូន៧នាក់ដោយខ្លួនគាត់ ហើយស្វាមីគាត់អត់សូវបានខ្វាយខ្វល់ពីក្រុមគ្រួសារឡើយរវល់តែស្រវឹង។ អ្នកមីងបានពុះពារគ្រប់បែបយើងដើម្បីកូន ហើយមានថ្ងៃមួយគាត់បានមានភ្លើងឆេះផ្ទះអស់ ធ្វើអោយគាត់អស់សង្ឃឹមក្នុងជីវិត ប៉ុន្តែជាការល្អវិញដែលមានមនុស្សជួយគាត់គ្រប់គ្នាដោយសារបានជួយសាងសង់ផ្ទះវិញហើយបានផ្តល់ជំនួយជាម្ហូបអាហារដល់គ្រួសារគាត់ ហើយអ្នកមីងគាត់ជាអ្នកជឿលើព្រះយេស៊ូវគ្រីស្ទ។ ហើយគាត់ក៏បានឆ្លងកាត់របបសង្គ្រាមហើយវាពិតជាលំបាកណាស់គាត់បានធ្វើការរហូតទោះឈឺក៏ដោយ អ្នកមីងបានត្រូវរត់ចេញពីកងទៅជាមួយមិត្តភក្តិ៥នាក់ដោយសារអត់មានអ្វីហូបក៏ស្លាប់២នាក់ទៅហើយអ្នកមីងរត់គេចហើយហូបដង្កូវនាងរហូត!!អ្នកមីងឥឡូវគាត់នៅតែពិបាកខ្លះៗតែគាត់ថាគាត់មិនសូវខ្វល់ខ្វាយដូចពេលមុនទេព្រោះកូនរបស់គាត់ធំៗអស់ហើយ។

កៈ សូមជំរាបសួរអ្នកមីង ខ្ញុំមានអារម្មណ៍សប្បាយរីករាយដែលបានមកសំភាសន៍អ្នកមីងនៅក្នុងថ្ងៃនេះហើយសូមអរគុណដែលបានអនុញ្ញាតអោយខ្ញុំសំភាសន៍អ្នកមីងហើយនាងខ្ញុំឈ្មោះញ៉ែម លាភី !! ហើយការសំភាសន៍នេះត្រូវបានធ្វើឡើងនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៨។ ហើយការសំភាសន៍នេះគឺស្ថិតនៅក្នុងភូមិ ទំនប់៩៩ វត្តទូលតាម៉ក់ ខេត្តកណ្តាល ហើយសុំទោសអ្នកមីងតើអ្នកមីងមានឈ្មោះពេញអ្វីដែរអ្នកមីង?

ខៈ ឈ្មោះខ្ញុំឈ្មោះសើម មាសអូន!!

កៈ សើម មាស!!

ខៈ ចា៎!!

កៈ ហ្នឹងទាំងត្រកូលទាំងឈ្មោះអីអញ្ចឹងណោះ?

ខ៖ ចាំចាំ ស៊ែម មាស!!

ក៖ ចាំ ហើយអើរអ្នកមីងដូចថាមានឈ្មោះហៅក្រៅអត់អ្នកមីង?គេដាក់ងារអោយ?

ខ៖ អត់មានទេ អត់មានទេ!!ឈ្មោះអញ្ចឹងតែម្តង ឈ្មោះខ្ញុំតែអញ្ចឹងមួយ។

ក៖ ចាំ ហើយអើរអ្នកមីងមានថ្ងៃខែឆ្នាំកំណើតនៅថ្ងៃទីប៉ុន្មានដែរអ្នកមីង?អ្នកមីងចាំអត់?

ខ៖ ថ្ងៃទី១០ ខែសីហាឆ្នាំ១៩៦៨។

ក៖ ចាំ ហើយទីកន្លែងកំណើតរបស់អ្នកមីងនៅទីណាដែរ?

ខ៖ ស្រុកកំណើតរបស់ខ្ញុំនៅភូមិអំពៅព្រៃ ឃុំកណ្តោរ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

ក៖ ចាំ អរគុណអ្នកមីង!! ហើយអ្នកមីងសព្វថ្ងៃរស់នៅកន្លែងណាដែរអ្នកមីង?

ខ៖ ខ្ញុំសព្វថ្ងៃរស់នៅទំនប់៩៤!! វត្តទួលតាម៉ក់។

ក៖ ចាំទំនប់៩៤ហ្នឹង??

ខ៖ ចាំ!!

ក៖ កណ្តាលហ្នឹងខេត្តកណ្តាលអ្នកមីងណោះ?

ខ៖ ចាំ!!ខេត្តកណ្តាល។

ក៖ ចាំអ្នកមីងអ្នកមីងឥឡូវ សព្វថ្ងៃអ្នកមីងធ្វើអ្វីដែរ?

ខ៖ ខ្ញុំសព្វថ្ងៃកសិករ លាងចាន តាមរោងការគេអញ្ចឹងទៅ!!

ក៖ ចាំ!

ខ៖ ប្តីធ្វើសំនង់ កូនធ្វើសំនង់ហ្នឹងអ៊ីចឹងទៅ!!

ក៖ ចាំចាំ!!

ខ៖ ដើម្បីយកជីវភាពហាហ្នឹងចិញ្ចឹមកូន!!ហើយនឹងអោយកូនរៀន យកលុយអោយកូនរៀន!!

ក៖ មកដល់ឥឡូវអ្នកមីងមានអាយុប៉ុន្មានដែរ?

ខ៖ ខ្ញុំ៥០គត់ហើយអូន!!

ក៖ ៥០គត់។ អ្នកមីងឆ្នាំខ្មែរឆ្នាំអីគេទៅ??

ខ៖ ខ្ញុំឆ្នាំខ្មែរខ្ញុំកើតនៅ!!

ក៖ ដូចថាឆ្នាំច ឬក៏ឆ្នាំខាល!!

ខ៖ ចាំខ្ញុំឆ្នាំរកា។

ក៖ ចាំឆ្នាំរកា!!

ខ៖ ចាំ!!

ក៖ ហើយអ្នកមីងស្គាល់អាឆ្នាំគេហៅថាភត្របទ ឆ្នាំខែចេត្រខែអីអត់អ្នកមីង?

ខ៖ អាហ្នឹងខ្ញុំកើតឆ្នាំរកាខែមាឃ!!

ក៖ ខែមាឃ!!

ខ៖ ចាំ!!

ក៖ អរគុណមីង ហើយមីងមានកូនប៉ុន្មាននាក់ដែរសព្វថ្ងៃនេះ?

ខ៖ ខ្ញុំកូនដែលរស់នៅ៧នាក់កូនត្រូវ៨នាក់ប៉ុន្តែស្លាប់មួយហើយនៅ៧នាក់។

ក៖ ចាំស្លាប់!! ហើយកូនស្រីប៉ុន្មានកូនប្រុសប៉ុន្មានដែរអ្នកមីង?

ខ៖ អើរកូនស្រី៥ប្រុស៣។

ក៖ ចាំ!!អើរដូចថាអ្នកមីងទីមួយអាយុប៉ុន្មានហើយគាត់នៅកន្លែងណាឬក៏?

ខ៖ ទីមួយអាយុ២៨ហើយគាត់មានប្តីហើយតែគាត់អត់មានកន្លែងជំរកនៅអញ្ចឹង ហើយគាត់រស់នៅជាមួយខ្ញុំនេះ!!នៅត្រង់នេះ!!

ក៖ ចាំចាំ!!

ខ៖ គាត់នៅត្រង់នេះនៅជាមួយខ្ញុំ។

ក៖ ហើយអើរគាត់មានកូនហើយឬនៅអ្នកមីង?

ខ៖ មានកូន៤ហើយ។

ក៖ ហ្អ៎មានច្រើនហើយ!!

ខ៖ ចាំ!!

ក៖ ហើយកូនៗគាត់ទៅរៀនអស់ហើយឬក៏យ៉ាងម៉េចដែរអ្នកមីង?

ខ៖ អត់ទេ កូនគាត់ទឹមតែបង២នោះអើរ អញ្ចេកប្តីទីមួយនោះការត្រឹមត្រូវតែគាត់លែងគ្នា ដូចថាកូនប្រសារខ្ញុំហ្នឹងគាត់តាមម៉ែក្មេកណាស់!!

ក៖ ចាំ!!

ខ៖ គាត់លែងកូនខ្ញុំអ៊ីចឹងទៅកូនប្រុសមួយគេយកទៅ នៅកូនស្រីមួយដែលរស់នៅជាមួយខ្ញុំតាំងពី៦ខែ តែឥឡូវគាត់យកប្តីក្រោយហ្នឹងគាត់បានកូន២!!អត់ទាន់មានកូនចូលរៀនទេ!!

ក៖ ចាំចាំ!!

ខ៖ ចាំ!!

ក៖ ចុះកូនទី២របស់អ្នកមីងមានអាយុប៉ុន្មានដែរហើយ?

ខ៖ កូនទី២អាយុ២៤ហើយអូន!!

ក៖ ចាំ!!

ខ៖ ២៤ឆ្នាំហ្នឹងហើយអូន!!

ក៖ ចាំ គាត់នៅរៀនតើអ្នកមីងណោះ?

ខ៖ គាត់អត់រៀនទេគាត់ឈប់តាំងពីថ្នាក់ទី៨ ដោយសារគាត់ឃើញខ្ញុំជីវភាពក្រីក្រអញ្ចឹងគាត់ជួយធ្វើការចិញ្ចឹមខ្ញុំ!!

ក៖ ចាំ!!

ខ៖ ចាំ!!

ក៖ ហើយគាត់ឈ្មោះអីគេដែរមីង?

ខ៖ គាត់ឈ្មោះអើរ សេក ពិសាល។

ក៖ សេក ពិសាល។ ចាំអញ្ចឹងបន្ទាប់មកទៀតអ្នកមីង?

ខ៖ បន្ទាប់មកទៀត សេក ស្រីលក្ខ័ សេក លក្ខិណា!!នេះគឺគាត់!!

ក៖ ចាំចាំ!!ស្អាតៗណាស់កូនមីង!!

ខ៖ ចាំ!!

ក៖ ហើយគាត់នៅផ្ទះជាមួយមីងហើយ មានធ្វើការងារអីផ្សេងៗ?

ខ៖ ចាំ គាត់នៅផ្ទះជាមួយខ្ញុំហ្នឹង គាត់ធ្វើការរោងចក្រ រវល់តែឈឺហ្នឹង!!

ក៖ ចាំ!!

ខ៖ គាត់ធ្វើខ្លះអត់ខ្លះអញ្ចឹងទៅណាស់!!

ក៖ ចាំ!!

ខ៖ ចាំ!!

ក៖ ហើយចុះកូនបន្ទាប់មកទៀតអ្នកមីង?

ខ៖ បន្ទាប់មកទៀតគាត់អាយុ២០ឆ្នាំ ឆ្នាំហ្នឹងហើយ ឆ្នាំខាល គាត់រៀនថ្នាក់ទី១២!!

ក៖ ចាំ បាននៅមានអ្នករៀនដែរ?

ខៈ ចាំ!!ហើយបន្ទាប់មកទៀតឆ្នាំរកា នេះឆ្នាំរកានេះ!!ហ្នឹ ភ្លេចអូននៅកូនស្រីមួយទៀត !!

កៈ ចាំ!!

ខៈ ឆ្នាំមមី!!តែគាត់នៅធ្វើការតាមផ្ទះនៅផ្ទះគេភ្នំពេញទេអូនណាស់!!

កៈ ចាំចាំមីង!!

ខៈ ចាំ!!ដើម្បីជួយម្ដាយ!!ហើយកូនមួយទៀតនេះគាត់ឆ្នាំរការនេះ!!

កៈ ចាំ!!

ខៈ គាត់នៅរៀន!!

កៈ ចាំ!!

ខៈ បន្ទាប់មកទៀតនេះ១១ឆ្នាំហើយ!!គាត់នៅរៀនដែរពៅគេ!!

កៈ ហើយចុះអ្នកមីងឪពុកម្ដាយរបស់អ្នកមីងគាត់ឈ្មោះអីគេដែរអ្នកមីង?

ខៈ អើរឪពុកម្ដាយគាត់ឈ្មោះ សើម ចក់(ឪពុកឈ្មោះសើម ម្ដាយឈ្មោះចក់)។

កៈ សើម ចក់!!

ខៈ ចាំ!!

កៈ គាត់ ឪពុក?

ខៈ ឪពុក ឪពុកឪពុកញ៉ុមទៀតហោ?

កៈ ឪពុកអើររបស់អ្នកមីងហាំ?

ខៈ ឪពុករបស់ខ្ញុំហ្នឹងឈ្មោះសើម?

កៈ ទាំងត្រកូល?

ខៈ សិទ្ធ សើម។

ក៖ ចាំ!!ចុះម្តាយ?

ខ៖ ម្តាយឈ្មោះកែម ចក់។

ក៖ កែម ចក់!!

ខ៖ ចាំ!!

ក៖ គាត់អាយុប៉ុន្មានហើយអ្នកមីង?

ខ៖ គាំតអើរឪពុករបស់ខ្ញុំស្លាប់បាត់ហើយ!!

ក៖ ចុះម្តាយ?

ខ៖ ម្តាយនៅ គាត់៧៧ ៧៨ហើយ!!

ក៖ ចាំចាំ!! គាត់នៅរស់សព្វថ្ងៃហ្នឹងអ្នកមីងណោះ?

ខ៖ គាត់នៅរស់ ម្តាយរបស់ខ្ញុំ។

ក៖ គាត់នៅកន្លែងណាដែរអ្នកមីង?

ខ៖ គាត់នៅភូមិអំពៅព្រៃហ្នឹង!!

ក៖ ចាំ!!ហើយចុះសុខភាពគាត់អត់អត់ដែរណោះអ្នកមីងណោះ?

ខ៖ គាត់ឈឺដែរហ្នឹង លើសឈាមលើសអី!!

ក៖ ហ្វាំ!! គាត់នៅតែផ្ទះតើអ្នកមីងណោះ?

ខ៖ ចាំ!!

ក៖ គាត់នៅជាមួយអ្នកណាគេទៅ?

ខ៖ គាត់នៅជាមួយប្អូនខ្ញុំ!!

ក៖ ចាំ!!

ខ៖ ៤នាក់។

ក៖ ចុះឪពុករបស់អ្នកមីងគាត់ស្លាប់ហើយ?

ខ៖ ស្លាប់ហើយ!!៣ខែជាងហ្នឹងហើយ។

ក៖ ហ៊ី កាលគាត់ស្លាប់គាត់អាយុប៉ុន្មានដែរអ្នកមីង?

ខ៖  កាលគាត់ស្លាប់គាត់អាយុ៧០ជាងដែរ!!គាត់បងប្អូនគាត់ បងគាត់អើរ គាត់បងម្តាយរបស់ខ្ញុំតែមួយឆ្នាំ!!

ក៖ គាត់ស្លាប់ដោយសារអីគេទៅអ្នកមីង?

ខ៖ គាត់ គាត់និយាយទៅជំងឺ គាត់ស្ងួតអញ្ចឹងទៅណាស់!!

ក៖ ចាំ!

ខ៖ ចាំ!!

ក៖ ហើយគាត់មានស្រុកកំណើតនៅឯណាដែរអ្នកមីង?

ខ៖ គាត់ស្រុកកំនើតរបស់គាត់នៅស្ពានបាក់នេះ ស្រីស្នំនេះ!!

ក៖ ចាំ!!

ខ៖ ប៉ុន្តែម្តាយខ្ញុំគាត់នៅស្រុកស្អាង!!

ក៖ ចាំ!! ហើយអញ្ចឹងឥឡូវម្តាយអ្នកមីងគាត់នៅតែផ្ទះទេ?

ខ៖ ចាំគាត់ធ្វើអីគេអត់កើតទេ!!

ក៖ ហើយចុះពេលឪពុកអ្នកមីងពេលគាត់នៅរស់គាត់ធ្វើការងារអីគេ?

ខ៖ គាត់ គាត់ពីដើមមកគាត់ឡើងត្នោតឡើងអីអញ្ចឹងទៅណាស់!!

ក៖ ចាំ!!

ខ៖ ពេលបែក៧៩(១៩៧៩)គាត់ឈឺពេលត្រឹមហ្នឹងមកគាត់ធ្វើអីគេអត់កើតគាត់ឈឺ គាត់ចេះតែដើរកំប៉ែកកំប៉ុកនៅក្បែរផ្ទះអញ្ចឹងទៅ!!

ក៖ ចាំ! ហើយកាលពេលគាត់ស្លាប់គាត់ស្លាប់នៅឯណាទៅមីង?

ខ៖ ស្លាប់នៅអំពៅព្រៃហ្នឹងដែរ។

ក៖ ចាំអំពៅព្រៃ!! ហើយគាត់មានដែលប្រាប់អ្នកមីងពីប្រវត្តិគាត់កាលពេលគាត់នៅពីក្មេងថាគាត់ធ្លាប់ឆ្លងកាត់អីគេខ្លះអត់អ្នកមីង?

ខ៖ អើរខ្ញុំគាត់អត់ដែលប្រាប់ទេ ប៉ុន្តែគ្រាន់ថាតាំងពីខ្ញុំនៅទូចនៅជាមួយគាត់អញ្ចឹងគាត់រកត្រីចងសន្ទូចចងអីអញ្ចឹងទៅណាស់!!

ក៖ ចាំចាំ!!

ខ៖ ញ៉ុមដើរកាប់នុយកាប់អីអោយគាត់អញ្ចឹងទៅ!!ហើយខ្ញុំជួយធ្វើការគាត់អីគាត់ហើយគាត់និយាយទៅគាត់កសិករដែរហ្នឹង!!

ក៖ ចាំ!!គាត់ធ្លាប់ធ្វើការអីគេផ្សេងពីហ្នឹងទៀតអត់អ្នកមីង?

ខ៖ គាត់ធ្វើស្រូវគាត់ឡើងត្នោតគាត់ដាក់សៃអីរកត្រីអីអញ្ចឹងទៅណាស់!!

ក៖ ចាំចាំ!!

ខ៖ តែប៉ុណ្ណឹង។

ក៖ ហើយគាត់ដូចថាមានដែលធ្លាប់ធ្វើការងាររដ្ឋអីផ្សេងៗ?

ខ៖ អត់ទេ អត់ទេ!!គាត់អត់ដែលទេ។

ក៖ ហើយគាត់មានដែលធ្លាប់និយាយអំពីប្រវត្តិជំនាន់អាពតជំនាន់អីគាត់មានដែលធ្លាប់អត់អ្នកមីង?

ខ៖ អត់ទេ ព្រោះខ្ញុំទាន់!!

ក៖ ចាំ!!

ខ៖ ជំនាន់អាពតខ្ញុំទាន់ខ្លួនឯងតែម្តង!!

ក៖ ចាំចាំ!! ចុះអ្នកមីងអាចរៀបរាប់ត្រួសៗថាពីដូចថាអ្នកមីងធ្លាប់ឆ្លងកាត់អីគេខ្លះកាលពេលជំនាន់ប៉ុល ពតហ្នឹង?

ខ៖ ចាំ ខ្ញុំរៀបរាប់បានតើអូន!! ជីវិតរបស់ខ្ញុំពេលជំនាន់អាពត អ៊ីចឹងបានខ្ញុំថា បច្ចុប្បន្នឥឡូវក្មេងឥឡូវនេះគាត់មិនដែលឃើញជំនាន់អាពតទេ!!

ក៖ ចាំ!!

ខ៖ បានជាគាត់មិនសូវដឹងណាស់!!តែខ្ញុំធ្លាប់ដឹងពីជំនាន់អាពត គឺខ្ញុំធ្លាប់ដឹងឆ្អែតពីឆាកជីវិតរបស់ខ្ញុំ!!អើរជំនាន់អាពតខ្ញុំអាយុ១២ឆ្នាំ ប៉ុន្តែខ្ញុំជាកងនារីដែរ គេយកខ្ញុំដាក់កងនារីទូចទូចណាស់!!

ក៖ ចាំ!ទូចទូចមួយសោះហ្នឹង!!

ខ៖ ចាំ!!នេះត្រើសជាងនេះបន្តិចទេ!!គេអោយខ្ញុំរែកដីនៅកោះខ្សាច់ជន្លៀ!!

ក៖ កោះខ្សាច់ជន្លៀហ្នឹងនៅណា?

ខ៖ កោះខ្សាច់ជន្លៀយើងនៅត្រើយកើតនេះ កោះទឹកវិលនេះ!!

ក៖ ចាំ!!

ខ៖ ដល់ហើយខ្ញុំរែកដីនេះខ្ញុំរុញធ្លាក់ ធ្លាក់ពីទំនប់ហ្នឹងមកផ្ងារក្រោយខ្ញុំរមៀលមកក្រោមមកណាស់!!

ក៖ ហ្វ៎!!

ខ៖ ដល់ខ្ញុំរែកលែងកើតគេដកខ្ញុំហ្នឹងយកទៅអោយរើសស្មៅសន្លឹក!!អាស្មៅភ្លួរដីហើយវាលមានស្មៅតែមួយទងមួយទង ចេះតែអោយយើងរើសទៅណាស់!!

ក៖ ចាំ!!

ខ៖ កណ្ដាលថ្ងៃត្រង់ម៉ោង១ម៉ោង១២!!ដល់ពេលគោះជួងអោយយើងហូបបាយអញ្ចឹង អូនមានតែបបរមួយកូនចានទេ!! គ្នារាប់រយបបរហ្នឹង ដូចថាអញ្ចេកបបរព្រលិតលាយជាមួយអង្ករ កាត់មួយថ្នាង១ដែរអញ្ចឹង!! អង្ករក្នុងមួយវែកហ្នឹងមានតែបួនដប់គ្រាប់ទេ!!!

ក៖ ចាំ!!

ខ៖ អញ្ចឹងខ្ញុំមានប្អូន ម៉ែខ្ញុំដែលមានប្អូនមួយទៀតដែលនៅផ្ទះមួយខ្ទបជាង គាត់ទៅធ្វើការបាត់ គាត់ទុកកូននៅចោលនៅនឹងផ្ទះហ្នឹងណាស់!!

ក៖ ចាំ!!!

ខ៖ វាចេះតែយំនៅនឹងផ្ទះតែឯងអញ្ចឹងទៅ ដល់ពេលហើយខ្ញុំអានិតប្អូនហ្នឹង ខ្ញុំចេះតែហូបតែអាព្រលិតហ្នឹងយកអង្ករហ្នឹងយកបបរហ្នឹងបញ្ចុកប្អូនទុកកាកកាកហ្នឹងណាស់!!

ក៖ ចាំ!

ខ៖ ចាំយកមកបញ្ចុកប្អូន!!ដល់ពេលញ៉ុមចេះតែរត់មកផ្ទះរត់មកផ្ទះដល់ហើយគេតាមខ្ញុំ គេតាមចាប់ខ្ញុំ ខ្ញុំនឹកម៉ែពេកនោះ!!

ក៖ ចាំ!!

ខ៖ គេតាមខ្ញុំមកដល់ ហើយម្ដាយខ្ញុំហ្នឹង !!គេចាប់យកទៅគេថាសាម៉ាក់មិត្តឯងរត់តាមម៉ែរហូត!!សាម៉ាកមិត្តឯងអត់គិតធ្វើការងារអោយអង្គការទេ ដល់ហើយគេដាក់ខ្នោះញ៉ុមអញ្ចឹងគេដាក់ច្រវ៉ាក់ ហើយគេជិះកង់ទៅអោយខ្ញុំរត់តាមកង់ដល់ខ្ញុំរត់អត់ទាន់ !!គាត់ផាក់ខ្ញុំដើរខ្ញុំយ៉ាងម៉េចទាន់ ហើយក្ដៅថៃស ដល់ហើយខ្ញុំក៏ដួល!!បើអូនមិនជឿទៅសួរម្ដាយរបស់ខ្ញុំរស់នៅរាល់ថ្ងៃ!!

ក៖ ចាំ!!

ខ៖ ដល់ពេលញ៉ុមដួលគេចេះតែផាក់ទៅគេចេះតែអូសអញ្ចឹងទៅ!!ហើយហុយសំពោង ហើយខ្ញុំដៃនៅជាប់រៀនកង់ហ្នឹង ខ្ញុំក៏ងាកហៅម្ដាយរបស់ខ្ញុំ ម៉ែមកម៉ែមក គាត់ថាទៅមុនទៅកូន!!ខ្ញុំក៏ទៅទៅដល់ណោះគេកសាង គេថាសាម៉ាក់មិត្តឯងបើសិនជារត់មកម្ដងទៀតគេយកម៉ែឪទៅកសាងហើយ!!

កៈ ចាំ!!

ខៈ ញ៉ុមនឹកឃើញថាខ្លាចម៉ែឪញ៉ុមស្លាប់ក៏ខ្ញុំអត់ទៅហ្នឹងទៅខ្ញុំខ្លាចម៉ែខ្ញុំស្លាប់!!ខ្ញុំក៏គេចចេញពីកន្លែងកងនារីហ្នឹង ខ្ញុំគេចចេញខ្ញុំក៏ទៅនៅក្នុងស្រូវសន្ទូងខ្ញុំទៅដេកនៅតាមភ្លឺស្រែណាស់!!ខ្ញុំអត់អីហូបទេ ខ្ញុំដកដង្កើមស្រូវហ្នឹងហូប ហើយខ្ញុំដើរដេកអញ្ចឹងទៅគេឃើញអញ្ចឹងគេរកខ្ញុំទៅកសាងខ្ញុំពួនគេតាមរកនោះ!!

កៈ ចាំ!!

ខៈ ខ្ញុំក៏លែងហ៊ានដកក៏រកបានខ្យងមួយពីរអញ្ចឹងខ្ញុំខ្វៃសយកក្បាលវាមក កូតអាសន្លឹកស្រូវហ្នឹងណាស់អូន!!

កៈ ចាំ!!

ខៈ កូតអោយវាអោយអស់រំអិលណាស់អូនហើយយើងហូបអញ្ចឹងទៅណាស់!!

កៈ ចាំ!!

ខៈ ហូបសាប។

កៈ ហូបទាំងឆៅ?

ខៈ ចាំ ហូបឆៅណាស់!!រួចទៅញ៉ុមនៅអត់បានទេញ៉ុមអត់មានអីហូប ញ៉ុមចេះតែដើរដើរអញ្ចឹងទៅ ហើយដល់ពេលថ្ងៃមួយអូនអើយទៅដល់សហាករណ៍ធំគេ ខ្ញុំឃើញគេ ខ្ញុំមើលគេពេលល្ងាច ខ្ញុំឃើញគេដាំបាយឆ្នាំងធំ មានត្រីងៀតមានអីណាស់ !!

កៈ ចាំ!!

ខៈ មុនដំបូងគ្នាខ្ញុំ៥នាក់ញ៉ុមដើរជាមួយគ្នាហ្នឹង!!ដល់ពេលហើយដាក់ខ្សែ តឡើងអញ្ចឹងហា!!ឡើងលួចគេអូនណាស់!!

កៈ ចាំ!!

ខ៖ ឡើងលួចគេបើសិនជាគេទាន់គេសម្លាប់ចោលទាំងអស់ហ្នឹង!! ឡើង៣ ៤នាក់អត់រួចទេ ខ្ញុំណោះឡើងខ្ញុំឡើងដាក់ជាន់ករគ្នាឡើងញ៉ុមដាក់តោងអាខ្សែហ្នឹង លួចបានបាយមួយឆ្នាំងញ៉ុមហូបបានមួយអាទិត្យ!!

ក៖ ឡើងលើអីគេមីង?

ខ៖ តោងកៅអីនេះ!!

ក៖ ឡើងលើផ្ទះគេ?

ខ៖ ចាំ!! អាបង្អួចគេដាក់បាយពយួរបាយហ្នឹង!!

ក៖ ចុះគេអត់មានអ្នកណានៅក្នុងផ្ទះហ្នឹងទេហេ?

ខ៖ គេនៅក្នុងផ្ទះឯណោះ ប៉ុន្តែគេអត់ឃើញយើងលួចទេ ព្រលប់ងងឹតៗណាស់!!

ក៖ ហ្ហ៎!!

ខ៖ យើងចូលលួចក្រៅផ្ទះ!!

ក៖ ចាំ!!

ខ៖ វាឃ្លានពេកនោះ!!

ក៖ ចាំ!!

ខ៖ បាយមួយឆ្នាំប្រហែល៣កំប៉ុងទៅទុកហូបប្រហែលមួយអាទិត្យ!!គ្នា៥នាក់!!ដល់ពេលហើយអូនឯងមើល ញ៉ុមអត់បាយហ្នឹងញ៉ុមនាំគ្នាដើរដើរ ពួកម៉ាក់ខ្ញុំឃ្លានពេកទៅដល់ទ្រុងមាន់គេហ្នឹងទៅរើសអាចមន៍មាន់គេហូប គ្នាក៏ដាច់ខ្យល់ងាប់ទៅហើយមិនដឹងធ្វើម៉េចចោលទៅចេះតែដើរទៀតទៅ!!ពួកម៉ាក់ខ្ញុំមួយទៀតក៏ស្លាប់ទៀត ស្លាប់នៅ៣នាក់ ចេះតែនាំគ្នាដើរផឹកតែទឹកហ្នឹង !! ដល់តែថ្ងៃមួយអូនឯងឃើញចំការល្ហុតហ្នឹងមានតែខ្ចីបទេណាស់ ទៅនៅចំការល្ហុតហ្នឹងកន្លះខែអូនណាស់ !! ទៅនៅតែចុងចំការល្ហុតហ្នឹង បេះតែខ្ចីបល្ហុតហ្នឹងហូប ផឹកតែទឹករណ្ដៅខ្មោច ម៉ោង៥ឡើងគេបណ្ដើរមកហើយមួយខែអញ្ចឹងហិតល់ឬស្សី ក្មេងប៉ុណ្ណឹងហិកាន់គល់ឬស្សីហិ!!

កៈ ចាំ!!

ខៈ បណ្ដើរមួយខ្សែអញ្ចឹងទៅយកទៅរ៉ៃក្នុងរណ្ដៅហ្នឹង!!ហ្នឹងខ្ញុំនៅកោះខ្សាច់ជន្លៀណាស់!!

កៈ ហើយលបមើលឃើញគេកំពុងរ៉ៃហោ?

ខៈ ចាំខ្ញុំលបមើលគេឃើញ ដល់តែពេលហើយរ៉ៃមានអ្នកខ្លះអញ្ចឹងទៅរស់រដេររដរទាំងថ្លុក ឈាមអញ្ចឹងទៅងើបមកផ្ទះមកណាស់!!ខ្លះក៏ងាប់នៅហ្នឹង!!ដល់តែខ្ញុំស្រេកទឹកអញ្ចឹងខ្ញុំទៅចុះ បង់អាទឹកខ្មោចហ្នឹងផឹក!!

កៈ អូយ!!

ខៈ ខ្ញុំទៅខ្សុងអាទឹកហ្នឹងទេតើ!!យកមកហូបណាស់!

កៈ ហើយម៉េចទៅអ្នកមីង?

ខៈ ចេះតែហូបទៅ!!ភ្លៀងមកចេះតែដក់ចេះតែហូបទៅ!!តែខ្សុងអោយឆ្ងាយពីហ្នឹង!!

កៈ ចាំ!!

ខៈ វាមានដានជើងគោជើងអីណាស់!!

កៈ ចាំ!!

ខៈ ហូបដល់ហើយអូនអើយ ហូបចេះតែដើរដល់ពេលថ្ងៃមួយទៅដល់ចំយើងយាយចំការមន ហ្នឹង ក៏សុំគាត់នៅ សុំគាត់នៅបេះចំការមនអញ្ចឹងទៅ!!គេក៏ថាបើឃើញនារីហ្នឹងត្រូវទៅហៅ ប្រាប់គេណាស់!!

កៈ ចាំ!!

ខៈ គាត់ក៏លាក់ហើយម៉ែខ្ញុំគាត់តាមសួរគេថាហ៊ី សាម៉ាក់មិត្តមាសហ្នឹងងាប់បាត់ហើយ!!គេប្រាប់គាត់អញ្ចឹងណាស់!!

កៈ ចាំ!!

ខ៖ ក៏ខ្ញុំហ្នឹងហូបតែដង្កូវនាងទេអូន!!ដង្កូវនាងដល់ពេលចាស់ទៅក៏គេមិនយកមកស្ងោរចោល!! គេបង្កើតអាថ្មីទៅណាស់!!

ក៖ ចាំ!!

ខ៖ ខ្ញុំហូបដង្កូវនាងគាត់ឡើងខ្ញុំសូមស្មាទោសឡើងបត់ជើងមកចេញសុទ្ធតែដង្កូវនាង!!ហើយដល់ពេលហើយខ្ញុំខ្ពើមដង្កូវនាងដល់សព្វថ្ងៃហ្នឹងហ៎!!!ដល់ពេលបែក៧៩(១៩៧៩)៨មេសាហ្នឹងអូនណាស់!! ខែរះពេញបូរមីពីកើតភ្លឺថៃស រះមកមូលក្រឡង់តែម្ដង!!ដល់តែហើយទៅយាយយាយគាត់ថាស្អែកហ្នឹងមិនបាច់ទៅធ្វើអីទេ!!គេចែកខោអាវយើងអោយស្លៀកពាក់ក្នុងថ្ងៃស្អែកហ្នឹងគេអោយយើងហូបនំបញ្ចុកសម្លរការី ថ្ងៃស្អែកហ្នឹងណាស់!!

ក៖ ចាំ!!

ខ៖ គ្រាន់តែនំបញ្ចុក៣ឡាន គ្រាន់តែសម្លរការីញ៉ុមប្រាប់អូនឯង២៥ខ្ទះ!!

ក៖ គេធ្វើនៅទីហ្នឹងឬក៏ដឹងមកពីណាអ្នកមីង?

ខ៖ ចាំគេដាក់នំបញ្ចុកហ្នឹងអត់ដឹងដឹកមកពីណាទេតែសម្លរការីគេធ្វើនៅហ្នឹង!!

ក៖ ចាំ!!

ខ៖ នំបញ្ចុកហ្នឹងដឹកមកទាំងឡានទាំងឡានតែម្ដង!!៣ឡានណាស់!!ខ្ញុំទៅអញ្ចឹងទៅជាមួយយាយៗគេអោយហូប គេថាសាម៉ាក់មិត្តយើងថ្ងៃស្អែកជាប់លៀងអង្គការយើងជប់លៀងអោយយើងហូប រាប់ឆ្នាំហើយឥឡូវអោយយើងហូបអោយឆ្អែតតែម្ដង!! ការពិតខ្ញុំលឺសូវដែរចាស់ៗនិយាយ ហ្នឹងខ្ញុំឮសូវតែចាស់ៗនិយាយទេណាស់!!

ក៖ ចាំ!!

ខ៖ គាត់ថាបើសិនជាបានហូបថ្ងៃស្អែកហ្នឹងប្រហែលជាអស់ហើយ!!មនុស្សគឺថាស្លាត់ស្រុក។

ក៖ គេសម្លាប់ចោលអស់ហ្នឹងមីង?

ខ៖ ប្រហែលជាដាក់ថ្នាំពុល។

ក៖ ហ្វ៎!!ចាស់ៗគាត់ថាគេដាក់ថ្នាំណាស់!!

កៈ ចា៎!!

ខៈ ហូបហើយទៅអស់តែម្តង!!ស្រាប់តែមិនទាន់បានហូបអូនឯងខ្ញុំហ្នឹងកំពុងច្រៀងអាបទគេអោយខ្ញុំច្រៀង គេវ៉ៃអាស្គរគេហ្នឹង អាធុងអាឡាំងគ្រាប់ហ្នឹង!!

កៈ ចា៎!!

ខៈ ខ្ញុំក៏ច្រៀងគេអោយច្រៀងអាអីកោះខ្សាច់ជន្លៀកន្លែងយើងកសាងខ្លួនហ្នឹងអូនណាស់!!

កៈ ចា៎!!

ខៈ កន្លែងយុវជនកន្លែងសាម៉ាក់មិត្តគាត់អោយខ្ញុំច្រៀងណាស់!!

កៈ ចា៎!!

ខៈ ខ្ញុំភ្លេចអស់មួយកំនរហើយចាំបានតែប៉ុណ្ណឹង!!ក៏អូនអើយអូនឯងគិតមើលស្រាប់តែបែកម៉ោង៧កន្លះយប់ ខែភ្លឺអោយថៃស ចាស់ៗថាអូនបែកអាពតហើយ!! ខ្ញុំក៏ថាបែកអាពតម៉េច?បែកអាពតម៉េចទៅយាយ?បែកអាពតហើយនាំគ្នាទៅផ្ទះកូន ខ្ញុំមានតែភួយមួយខ្លួនទទេដើរមួយយប់ទល់ភ្លឺដើររកម៉ែ មិនដឹងផ្ទះម៉ែនៅឯណារកមិនឃើញ!!ដើរពេញទាំងអស់ខ្វាត់ខ្វែងអត់ដឹងថាផ្ទះម៉ែនៅឯណា??រកអត់ឃើញអូនឯងគិតមើលទៅមើល!! ដល់ហើយបានបែក៧៩(១៩៧៩)ហ្នឹងក៏ខ្ញុំឪខ្ញុំហ្នឹងក៏ឆ្លងពីទន្លេមកមកនៅជំលៀសមកអញ្ចឹងមកអត់មានអីទេ!!មានតែប៉ាងមួយក្រមាមួយទេបាយខ្ចប់ក្រមា !!

កៈ ចា៎!!

ខៈ ខ្ចប់ក្រមាដាំបាយប៉ាងមួយយើងស្លរទៅ!!ហ្នឹងបែក៧៩(១៩៧៩)ណាស់!!

កៈ ចា៎!!

ខៈ ដល់ពេលយើងបែក៧៩(១៩៧៩)ហើយចូលឆ្នាំ៨០(១៩៨០)គត់ ខ្ញុំកាប់អុសពីនោះពីព្រៃភ្នំខ្សាកហ្នឹង កាប់អុសពីហ្នឹងទៅណោះទូលទៅលក់នៅព្រែកហូរ!!

កៈ ចា៎!!

ខៈ ដូរអង្ករនៅព្រែកហូរអត់ទាន់មានលុយទេណាស់!!

កៈ ចាំ!!យកទៅដូរអង្ករនៅព្រៃកហូរ ចូលឆ្នាំ៨១(១៩៨១)មានក្រដាសមួយកាក់មួយកាក់ ៨១ (១៩៨១)ហ្នឹងមានក្រដាសយើងមួយកាក់មួយកាក់យើងចេញហើយ!!

កៈ អាកាក់យើងមូលៗហ្នឹងមីងហេ?

ខៈ អត់ទេក្រដាស!!

កៈ ក្រដាសលុយ?

ខៈ ចាំក្រដាសមួយកាក់មួយកាក់ប៉ុនៗហ្នឹង!!

កៈ ទូចៗ?

ខៈ ក្រដាសប្រវែងៗនេះ!!ប៉ុនៗពីរថ្មៀបក្រដាសមួយកាក់មួយកាក់ណាស់!!

កៈ ចាំ!!

ខៈ ចាំ!!

កៈ ញុំមអត់ទាន់។

ខៈ អត់ទាន់ទេអូនឯង កើតអត់ទាន់ទេ!!អូនឯងដឹងយ៉ាងម៉េចទេ ខ្ញុំក៏ទូលអុសយកមកដូរអង្ករដូរអីអញ្ចឹងទៅ!!ដល់តែហើយបានលុយបានឡើងថ្លៃហើយ មួយបាច់ហ្នឹងបាន៥រៀល។

កៈ ចាំ!!

ខៈ មូលដូចកង់រទេះអីចឹង!!ទូលទៅលក់នៅព្រៃកហូរហ្នឹងរហូត!!

កៈ ហើយទូលទៅឆ្ងាយដែរមីង?

ខៈ ចាំទូលទៅ ទូលតាំងពីអំពៅព្រៃហ្នឹងហ៎ា ដើររហូតទៅដល់ព្រៃកហូរហ្ន៎!!

កៈ អត់មានអីដឹកទេមីង?

ខៈ អត់ទេ!!កាលហ្នឹងអត់មានអីទេទូល!!

កៈ ចាំ!!

ខ៖ ទូលតាមផ្លូវ ថាជីវិតរបស់ខ្ញុំវេទនាណាស់អូនណាស់ អញ្ចឹងបានខ្ញុំថាអោយតែខ្ញុំនេះខ្ញុំសួរក្មេងៗថាអូនឯងមានដឹងទេក្មេងៗទាំងអស់គ្នា?សព្វថ្ងៃហ្នឹងមានរសជាតិប៉ុន្មានយ៉ាង?រសជាតិ៥យ៉ាង មានជូរ មានចត់ មានល្វីង មានផ្អែម ហើយជីវិតរបស់យើងអូនណាស់!!!

ក៖ ចាំ!!

ខ៖ អញ្ចឹងបានថាក្មេងឥឡូវអត់ដឹងទេ!!ស្រួល!! ហើយគ្រាន់តែអោយរៀនស្រាប់សោះក្មេងៗអត់រៀនផង គិតតែដើរលេង!!

ក៖ ចាំ!!

ខ៖ អត់គិតថាកន្លែងណាដែលសង្គមស្អប់ខ្ពើមយើងដើរចេញអត់ទេ រឹតតែប្រព្រឹត្ត!!

ក៖ ហ៊ឺ មីងឆ្លងកាត់ដូចជាពិបាកច្រើនដល់ហើយ!!

ខ៖ ចាំ ញ៉ុមឆ្លងកាត់ពិបាកច្រើនណាស់អូន!!

ក៖ ចាំ!!

ខ៖ ហើយខ្ញុំទំរាំញ៉ុមបានការមានប្តីមក មកបានប៉ុណ្ណេះក៏ខ្ញុំបានឆ្លងកាត់ជីវិតរបស់ខ្ញុំ ខ្ញុំប្រាប់អូនឯងកូន៧នាក់ណាស់ ខ្ញុំស៊ីឈ្នួលស្ទូងគេណាស់!!ខ្ញុំបានខ្យងមួយបង្វេច ថ្នក់សំពត់មកហាមកដល់ផ្ទះបុកម្ស៉ៅត្រាំម្ស៉ៅបុក។

ក៖ អង្ករមែនអ្នកមីង?

ខ៖ ចាំត្រាំអង្ករអញ្ចឹងទៅបុកជាម្ស៉ៅស្លរអោយកូនហូបហាំ!!មកវិញអត់ទាន់ចូលដល់ផ្ទះទេ ដើរបោចស្លឹកកន្ទោប ស្លឹកងប់យើងហ្នឹងបោចស្លឹកងប់បោចស្លឹកបាសតាមភ្លឺស្រែមក យកមកស្លរអោយកូនហូប!!

ក៖ ស្លរម្ស៉ៅហ្នឹងស្លរម៉េចទៅមីងញ៉ុមអត់ដែលស្លរផង?

ខ៖ ស្លរម្ស៉ៅហ្នឹងយើងបុកគ្រឿង។

ក៖ បុកគល់ស្លឹកគ្រៃហ្នឹង?

ខ៖ ចាំ!!យើងបុកស្លឹកគ្រៃហ្នឹងអោយម៉ត់ជាមួយខ្ទឹមអីហើយជាមួយខ្ញៀយអ៊ីចឹងបុកអោយម៉ត់ហើយ!!

ក៖ ចាំ!!

ខ៖ ម្សៅយើងបុកអោយម៉ត់!!

ក៖ ចាំ!!

ខ៖ ពេលយើងដាំទឹកពុះហើយយើងជ្រំប្រហុកហើយយើងដាក់អើរម្សៅអង្ករហ្នឹងឆ្អិនហើយយើងបង់ខ្យងហ្នឹងអោយឆ្អិនទៅ យើងបង់បន្លែយើងដាក់គ្រឿងហ្នឹងទៅ!!

ក៖ ចាំ!!

ខ៖ ចាំ!!

ក៖ ម្សៅហ្នឹងទៅ?

ខ៖ ចាំ!!សម្លរខ្មែរយើងពិតប្រាកដអត់មានគីមីទេ!!!

ក៖ ញ៉ុមអត់ដែលធ្វើអាហ្នឹង!!

ខ៖ ហ្នឹង !!ហើយខាប់ៗ!!

ក៖ ចាំ!!

ខ៖ នាំកូនហូបទៅ!!

ក៖ ស្លរត្រីអីក៏បានដែរអ្នកមីងណោះ?

ខ៖ អាហ្នឹងអើរអត់ស្លរត្រីកើតទេ!!បើយើងស្លរតែខ្យងហើយនឹងខ្ញៅអាហ្នឹងបាន!!

ក៖ ហ៊ឹមានអញ្ចឹងទៀត!!

ខ៖ ចាំ!!ហើយយើងដាក់កញ្ជ្រោលភ្នំដាក់អីអញ្ចឹងមក ហ្នឹងស្លរម្សៅ។

ក៖ ដាក់កញ្ជ្រោលភ្នំដែរ?

ខ៖ ចាំ!!ខ្ញុំឆ្អែតហើយអូនណាស់ទំរាំតែបានកូនខ្ញុំប៉ុនៗនេះណាស់!!ជីវិតខ្ញុំណាស់ ទូលអុសលក់ចិញ្ចឹមកូននេះ!!មីមួយនៅធ្វើការអោយគេហ្នឹងហាំ ញុំមកើតបានតែ៣ខែទេណាស់ ដីឪក្មេកញុំមអោយគាត់ឈ្លោះជាមួយប្តីខ្ញុំគាត់ដកដីញុំមយកណាស់គាត់អត់អោយទេ គាត់អត់ចែកអោយខ្ញុំទេ!!ខ្ញុំស៊ីឈ្នួលគាស់គល់គេណាស់ កូនខ្ញុំមីមួយធ្វើខ្ញុំគេបានប្តី ខ្ញុំកើតបាន៣ខែខ្ញុំធ្វើការ ខ្ញុំម៉ោងគាស់គល់គេ៣០០០០០ញុំមខ្ចីលុយគេ១០០០០០មុនយកមកទិញដីហ្នឹងហិ ៥ម៉ែត្រហ្នឹង៥០០០០លុយខ្មែរហិ!!

កៈ ទិញយូរហើយអ្នកមីងហោ?

ខ៖ ចាំញុំមទិញយូរណាស់ហើយ!!៥ម៉ែត្រហ្នឹង៥០០០០លុយខ្មែរអូនណាស់!!

កៈ ចាំ!!

ខ៖ ខ្ញុំយកលុយគេមកខ្ញុំធ្វើផ្ទះនៅខ្ញុំទិញដីហ្នឹង ញុំមប្រាប់អូនឯងញុំមវេទនាណាស់ទំរាំកូនខ្ញុំបានប៉ុណ្ណឹងហិ!!

កៈ ចាំ!!

ខ៖ នេះកូនខ្ញុំដែរហិអូន!!

កៈ ចាំ!!

ខ៖ គ្នាធ្វើការសំណង់ដែរ!!ខ្ញុំពិបាកពីមុនខ្ញុំអត់។

កៈ ចាំហ៊ីអានិតណាស់មីងដូចថានៅក្មេងៗអត់បានរៀនអត់បានអីអញ្ចឹងណាស់!!

ខ៖ ចាំ!!ញុំមអត់បានរៀនទេអូន ញុំមបានរៀនដែរបានរៀនយ៉ាងម៉េចព្រោះអីញុំមជាកូនចិញ្ចឹមរបស់គាត់ មុនទៅរៀនណាស់ មុជទឹកអោយប្អូនហើយចងគោ ដាំបាយទុកដាក់អោយហើយព្រោះម៉ែខ្ញុំគាត់ឈឺណាស់!!

កៈ ចាំ!!

ខ៖ ខ្ញុំរត់ហាខ្ញុំដោះអាវញុំមប្រាប់អូនឯងខ្ញុំរត់ហាំ!!កាន់តែសៀវភៅហ្នឹងមួយទៅហើយញុំមរៀនបានថ្នាក់ទី៣ដែរ!!

កៈ ទី៣?

ខៈ ចាំ!!

កៈ មកដល់ឥឡូវមីងចេះអានអក្សរខ្មែរចេះមើលអីទេ?

ខៈ ខ្ញុំចេះខ្លះៗ។ពេលមុនខ្ញុំរៀនបានថ្នាក់ទី៣ខ្ញុំបានគេអោយធ្វើកុមារឈាមមុនទៀត!!

កៈ ចាំ!!មីងរៀននៅឯណាវិញមីង?

ខៈ ខ្ញុំរៀននៅគោករមៀត មន្ទីរគោករមៀតហ្នុំ!!

កៈ គោករមៀតហ្នឹងនៅខេត្តហ្នឹងដែរតើមីងណោះ?

ខៈ ចាំ!!

កៈ ខេត្តកណ្តាល!!

ខៈ ខេត្តកណ្តាលយើងហ្នឹង!!

កៈ ចា!!

ខៈ ជីវិតរបស់ខ្ញុំជូរចត់ណាស់អូន អញ្ជឹងបានខ្ញុំថាទំរាំខ្ញុំបានប៉ុនេះជូរចត់ មានអស់ហើយមានប៉ុន្មានមុខហ្នឹង ខ្ញុំមានប្រាំមុខ ខ្ញុំរៀនឆ្អែតហើយ!!

កៈ ចាំ!!តែមីងទៅរៀនមីងមានរៀនភាសាផ្សេងទេមីង?

ខៈ អត់ទេញ៉ុមរៀនបានតែខ្មែរហ្នឹង!!

កៈ តែខ្មែរ!!

ខៈ ចាំ!!

កៈ ព្រោះអីញ៉ុមធ្លាប់ឮពេលមុនថាមានគេធ្លាប់បញ្ចូលភាសាបារាំងអោយចូលរៀនអញ្ជឹង!!

ខៈ ខ្ញុំអត់ទេ ខ្ញុំបានតែខ្មែរទេ បានពួកម៉ាក់ខ្ញុំណាស់គេរៀនបានអាំងស៊ីញ៉័រហ្នុំ!!

កះ ចាំ!!

ខះ ហើយខ្ញុំបានតែខ្មែរ បានតែថ្នាក់ទី៣ហ្នឹង!!ញ៉ុមអត់បានរៀនទៀតទេ គាត់អត់អោយទៅរៀនទេគាត់វ៉ៃញ៉ុម។

កះ មីងនៅជាមួយម្ដាយបង្កើតឬក៏នៅជាមួយម្ដាយចិញ្ចឹម?

ខះ ម្ដាយចិញ្ចឹមតើ!!

កះ ហើយចុះម្ដាយបង្កើតរបស់អ្នកមីងម៉េចបានអត់នៅជាមួយ?

ខះ ម្ដាយបង្កើតរបស់ខ្ញុំគាត់ស្លាប់ចោលខ្ញុំហ្នឹង!!

កះ ហ្ហ៎!!

ខះ ឪពុកខ្ញុំមានប្រពន្ធទៀត គាត់យកខ្ញុំចោលហ្នឹង!!

កះ ចាំ!!

ខះ ហ្នឹងយាយខ្ញុំគាត់និយាយប្រាប់ទេណាស់!!!

កះ ចាំ!!

ខះ យកខ្ញុំចោលគាត់មានចិញ្ចឹមខ្ញុំឯណា!!

កះ នៅរស់សព្វថ្ងៃហ្នឹងម្ដាយចិញ្ចឹមទេ?

ខះ ចាំ!!

កះ ហើយចុះម្ដាយបង្កើតមីងធ្លាប់ដឹងពីគាត់ខ្លះដែរម៉េចអត់?

ខះ ម្ដាយបង្កើតគាត់នៅស្ពានបាក់ហ្នឹងដែរតែញ៉ុមអត់ដែលដឹងវីវរល់អីផងមិនដឹងយ៉ាងម៉េចអីយ៉ាងម៉េចអីផង!!

កះ អើរមកដល់ឥឡូវអត់ដឹងដំណឹងគាត់តែម្ដង?

ខះ ដឹងដំណឹងប៉ុន្ដែញ៉ុមអត់ដែលទៅគាត់ទេ!!

កៈ ចាំ!

ខៈ ចាំ!!

កៈ ដោយសារគាត់បោះបង់មីងចោល?

ខៈ ចាំគាត់បោះបង់ញ៉ុមចោល!! គេចេះតែថា ង៉ែងអត់ទៅម៉ែង៉ែងឈឺ!! ញ៉ុមថាញ៉ុមដូចអត់និស្ស័យទេ ញ៉ុមនិយាយអោយត្រង់តែម្តងអូន!!ព្រោះញ៉ុមឈឺញ៉ុមបានម៉ែចិញ្ចឹមញ៉ុមចិញ្ចឹម ព្រោះខ្ញុំអត់ពីគាត់ក៏ខ្ញុំងាប់ដែរ!!!!

កៈ ចាំ!!

ខៈ គាត់ខឹងឪពុកខ្ញុំគាត់យកខ្ញុំទៅក្រវត្តចោលហ្នឹង គាត់មានចិញ្ចឹមខ្ញុំឯណា !!យាយញ៉ុមបង្កើតគាត់និយាយប្រាប់ណាស់!!

កៈ ចាំ!!

ខៈ ហើយបងខ្ញុំមួយទៀតអោយទៅខាងឪពុកខ្ញុំហ្នំ!!

កៈ ចាំ!!

ខៈ ពីរនាក់បងប្អូនបែកបាក់គ្នា។

កៈ អញ្ចឹងឪពុកមីងអ្នកទឹមតែស្លាប់ហ្នឹងឪពុកបង្កើត?

ខៈ ឪពុកចិញ្ចឹមទេ។

កៈ ឪពុកចិញ្ចឹមទេ!!!

ខៈ ចាំ!!ឪពុកបង្កើតញ៉ុមអត់ដឹងទេ ប៉ុន្តែយាយញ៉ុមនិយាយថាគេសម្លាប់នៅក្នុងជំនាន់អាពតបាត់ហើយ!!!

កៈ ហ្នំ!!

ខៈ ឪពុកខ្ញុំគាត់នាយកសាលាហ្នឹងយាយខ្ញុំនិយាយទៅណាស់!!!!

កៈ ចាំ!!

ខៈ ឪពុកខ្ញុំបង្កើតហ្នឹង!!

កៈ ចាំ!!ទឹមតែបែក៧៩(១៩៧៩)យើងដល់មក៩៣(១៩៩៣)ហ្នឹងបានគាត់និយាយប្រាប់ខ្ញុំ គាត់ជួបខ្ញុំគាត់និយាយប្រាប់ខ្ញុំណាស់!!!

កៈ ហ្នឹងហើយ!!

ខៈ គេសម្លាប់ជំនាន់អាពតបាត់ហើយ!!អត់ទាន់ឃើញមុខឪពុកហ្នឹងយ៉ាងម៉េចផង!!!!

កៈ ហ្វូមីងអត់ដែលស្គាល់សោះតែម្តង?

ខៈ ចាំអត់ដែលស្គាល់សោះតែម្តង។

កៈ តែម្តាយធ្លាប់ឃើញមុខដែរ?

ខៈ ចាំម្តាយឃើញមុខ!!!

កៈ ចាំ ពេលដែលជួបយើង គាត់និយាយធម្មតាឬក៏ម៉េច?

ខៈ និយាយជាមួយយើងធម្មតាមុនដំបូង ដល់ពេលញ៉ុមការហើយញ៉ុមក្រអញ្ចឹងណាស់ ការហើយញ៉ុមអត់មានអីទេ ខ្ញុំទៅលេងគាត់ ខ្ញុំបាន២០០០ខ្មែរជូនគាត់ គាត់ដៀលខ្ញុំហាំ!!ពីមុនញ៉ុមរាប់គាត់ដែរ សុទ្ធដៀលខ្ញុំដូចថាគាត់ឃើញតែអ្នកមានលុយអញ្ចឹងទៅណាស់!!

កៈ ចាំ!!

ខៈ ដល់ខ្ញុំខ្ញុំអត់អញ្ចឹងគាត់អត់រាប់ទេ!!

កៈ ចាំ!!

ខៈ គាត់ថាមកកាត់ស្រុកមួយស្រុកពីរយក២០០០មកជូនគាត់!!ញ៉ុមក៏ខ្មាស់គាត់ញ៉ុមក៏ឈប់រាប់គាត់រហូត!!ឈប់រហូត។

កៈ យើងអត់ដែរ!!

ខ៖ ចាំ!!ឈប់រហូតទល់៣០ឆ្នាំហ្នឹងទៅទល់ឥឡូវ។

ក៖ ចាំ!!

ខ៖ ខ្ញុំការមក២៨ឆ្នាំ២៩ឆ្នាំហើយមកឥឡូវ។

ក៖ ឥឡូវគាត់នៅរស់តើអ្នកមីងណោះ?

ខ៖ គាត់នៅដល់រាល់ថ្ងៃ។

ក៖ គាត់ឈ្មោះអីគេអ្នកមីង?

ខ៖ គាត់ឈ្មោះអើរ នេះគាត់នៅស្ពានបាក់គាត់ឈ្មោះយាយមឿន!!

ក៖ យាយមឿន?

ខ៖ ចាំ!!!ញ៉ុមអត់ដែលគិតគូរគាត់ទេ!!

ក៖ ហើយឪពុកអត់ធ្លាប់ឃើញមុខសោះ?

ខ៖ អត់សោះ!!

ក៖ ហើយអើរម្ដាយបង្កើតរបស់មីងហ្នឹងយកទៅអោយម្ដាយចិញ្ចឹមរបស់មីងយកមកចិញ្ចឹមហ្នឹងទៅ?

ខ៖ គាត់សុំហ្នឹងគាត់អត់អោយទៀត គាត់សុខចិត្តយកដាក់ចោល!!ដាក់ចោលហ្នឹងបានឪពុកចិញ្ចឹមរបស់ញ៉ុមហ្នឹងគាត់ទៅលួចយកមក!!

ក៖ ចាំ!!

ខ៖ ចាំ!!គាត់ថាចង់អោយងាប់ដាច់ពូជអញ្ចឹងទៅណាស់!!

ក៖ ចាំ!!

ខ៖ ហ្នឹងហើយ!!

ក៖ ហើយមីងអត់មានបងប្អូនបង្កើតណាមីង?

ខ៖ បងប្អូនបង្កើតគេអត់ដែលរាប់ញុំមទេ។

ក៖ តែគេមាននៅរស់ដែរ?

ខ៖ គេនៅរស់រាល់ថ្ងៃហ្នឹង គេនៅផ្សារក្រមួនចាក់អង្រែហ្នឹង គេអត់ដែលរាប់ខ្ញុំទេអូន យើងក្រ គេមានយើងក្រអញ្ចឹងគេអត់ដែលរាប់ញុំមទេ!!

ក៖ ចាំ!!

ខ៖ ញុំមនិយាយអោយត្រង់សួរកូនខ្ញុំទាំងអស់មើល!!

ក៖ ចាំ!!

ខ៖ ខ្ញុំអត់ហ៊ានទៅក្បែរគេទេកុំអោយគេថាយើងទៅរកសុំគេ!!!

ក៖ ចាំ!!

ខ៖ ព្រោះអីញុំមទៅលេងម្តងពីរដងវាថាហ៊ី ដល់ពេលទៅផ្ទះគេប៉ុណ្ណាណរីគេមានឡានហ្វំ!!

ក៖ ចាំ!!

ខ៖ ដល់ពេលយើងទៅទៅវាថាប្អូនអញឥឡូវឈឺរកអីអត់បាន!!ញុំមទៅថាដូចថាទៅរកគេអីគេ គេទេ ញុំមទៅដូចថាអញ្ចេកដូចថាឈាមឪពុកវាមានតែពីរនាក់បងប្អូនអីចឹងចង់ទៅរាប់បងអោយវាមានសាច់ញាតិ!!

ក៖ ចាំ!!

ខ៖ ដល់ពេលគេនិយាយអីចឹងញុំមសុខចិត្តអត់ធ្វើម៉េចញុំមថាអត់ទៅហើយមួយជីវិតអត់ទៅហើយឯកកោហើយ វាឯកកោតែឯងអញ្ចឹងតែម្តងទៅ!!

ក៖ អញ្ចឹងមីងមានបងប្អូនបង្កើតតែពីរនាក់ហ្នឹងទេ??

ខ៖ ចាំ!!

ក៖ ស្រីឬក៏ប្រុសមីង?

ខ៖ ស្រី!!!

ក៖ ចាំ គាត់បងមីងណោះ?

ខ៖ ចាំគាត់បងបង្កើត!!តែអាហ្នឹងធ្វើយ៉ាងម៉េចអាហ្នឹងតាមយថាកម្មរបស់ខ្ញុំអញ្ចឹងទៅ!!

ក៖ ចាំ!!

ខ៖ ខ្ជិលទៅជិតគេកុំអោយគេថាយើងទៅរកគេអូនណាស់!!

ក៖ ចាំ!!

ខ៖ បើយើងអត់ បើយើងទៅគេថាយើងទៅរកគេហើយ!!

ក៖ ចាំ!!

ខ៖ អញ្ចឹងញ៉ុមអត់ទៅជិតគេទេ!!!ថាអត់មានញាតិបងប្អូនចុះ!!!

ក៖ ចាំ!!ចុះមីងគ្រួសាររបស់មីងសព្វថ្ងៃគាត់អើរទៅធ្វើការងារអ្វីដែរអ្នកមីង?

ខ៖ ញ៉ុមនិយាយទៅញ៉ុមអត់មានលាក់កំបាំងអីមីងទេអានេះក៏មិនថាហែកកេរ្តិ៍ប្តីដែរ ព្រោះគាត់អញ្ចេកពេលមុនកូនមួយកូនពីរគាត់ចេះតែជួយរកខ្ញុំខ្លះអត់ខ្លះអីអញ្ចឹងទៅណាស់!!

ក៖ ចាំ!!

ខ៖ ពេលខ្ញុំត្រឹមកូនទី៤ គាត់អត់មានជួយរកខ្ញុំទេអូន!!គាត់ហូបរហូតគាត់ហូបមួយថ្ងៃមួយថ្ងៃវាស់ល្ងាចគាត់អត់ធ្វើអីសោះគាត់អត់ជួយរកអីសោះ ហើយកូនឡើងរញ៉ុងទូចទូចខ្ញុំប្រាប់មីអូនឯងណាស់ខ្ញុំងើបតាំងពីម៉ោង១២ ដាក់មងដើម្បីយកលុយមកទិញអង្ករអោយកូនស៊ីណាស់!! ញ៉ុមប្រាប់ណាស់ កូន៧នាក់ញ៉ុមចិញ្ចឹមតែម្នាក់ឯងណាស់!!បានដល់សព្វថ្ងៃហ្នឹងក៏គាតហូបរហូត គាត់ទឹមតែទៅធ្វើការ២អាទិត្យហ្នឹងទេ!!ហ្នឹងដោយសារខ្ញុំនិយាយអោយអស់ទៅខ្ញុំឈ្លោះគ្នាជាមួយគាត់ ខ្ញុំក៏ថាថាឥឡូវញ៉ុមឯងទៅនៅឯណាមានក្តីសុខទៅចុះបើឯងឥឡូវឯងអត់ដឹងថាឥឡូវកូនឈឺក៏គាត់មិនដឹងឮមើល ដល់តែញ៉ុមយកកូនទៅពេទ្យគាត់មិនដែលថាដឹងកូនទៅពេទ្យ កូនឈឺ អត់ដែលដឹងទេអូន!!!និយាយអីដូចអ្នកដទៃតែម្តង!!!

ក៖ ចាំ!!

ខ៖ តែខ្ញុំទេ ជំពាក់គេខ្ចីគេបុលគេដើម្បីយកកូនទៅពេទ្យដើម្បីអោយកូនរស់រានមានជីវិត ញ៉ុម ប្រាប់អូនឯងជីវិតខ្ញុំឆ្អែតវេទនាណាស់!!

ក៖ ចាំ!!

ខ៖ បានញ៉ុមនិយាយញ៉ុមជីវិតញ៉ុម ញ៉ុមមិនចង់និយាយ ដល់ពេលហើយញ៉ុមចិញ្ចឹមកូនរបស់ខ្ញុំប៉ុនៗនេះមកដោយសារកំលាំងញ៉ុម ខំស្វះស្វារ ដល់ពេលហើយគាត់មានគិតថាស្រលាញ់ប្រពន្ធស្រលាញ់កូនរកស៊ីចិញ្ចឹមប្រពន្ធចិញ្ចឹមកូនរកស៊ីមានបាន គាត់អត់គិតទេ !! ពេលអាទិត្យមុនខ្ញុំឈ្លោះគ្នាជាមួយគាត់ ញ៉ុមសារអីវ៉ាន់គាត់ដាក់លើពាង គាត់ខឹងញ៉ុមសារអីវ៉ាន់គាត់គាត់រើរអីវ៉ាន់ខ្លួនគាត់គាត់ដើរប្រាប់គេថាញ៉ុមដុតខោអាវគាត់ដុតអីវ៉ាន់គាត់!!គាត់ដុតខ្លួនគាត់ទេណាស់!!

ក៖ ចាំ!!

ខ៖ ដល់ពេលហើយខ្ញុំអត់និយាយរកគាត់ទេ!!គាត់នៅតែគាត់ញ៉ុមនៅតែញ៉ុមទៅប្រហែលជាជិតមួយឆ្នាំហើយ!!

ក៖ តែគាត់ត្រលប់មកផ្ទះហ្នឹងដែរមីងហោ?

ខ៖ គាត់មកតែគាត់សំរានគ្រែក្រោម ខ្ញុំដេកជាមួយកូននៅលើផ្ទះ។

ក៖ ចាំ!!

ខ៖ គាត់អត់អីហូប គាត់រករឿងគាត់ស្រវឹងគាត់មករកបោកចានបោកឆ្នាំង !!ប៉ុន្តែគាត់អត់ហ៊ានជាមួយខ្ញុំដែរពីព្រោះអីខ្ញុំខ្លាំងដែរ!!!

ក៖ ចាំ!!

ខ៖ ពីព្រោះអីខ្ញុំចាយលុយរបស់ខ្ញុំកំលាំងរបស់ខ្ញុំ ខ្ញុំថាខ្ញុំដើររកកំលាំងខ្ញុំចង់ទិញអីអោយកូនហូបខ្ញុំចង់ទិញអីអោយកូនគឺជាលុយរបស់ខ្ញុំ!!ហ្នឹងខ្ញុំប្រាប់អូនត្រង់ បានមីមួយនេះជួយខ្ញុំ រកលុយទុកមីនេះសំរាប់ពេលឈឺ ឈាមសរស៊ីឈាមក្រហម!! មើលកូនបណ្តើរធ្វើការបណ្តើរ រួមគ្នាធ្វើការបណ្តើរឈឺបណ្តើរ។

ក៖ មីងរៀបការហើយប៉ុន្មានឆ្នាំហើយអ្នកមីង?

ខ៖ ខ្ញុំតាំងពី៨៩(១៩៨៩)។

ក៖ ៨៩(១៩៨៩)ឥឡូវ៣០ឆ្នាំជាងហើយអ្នកមីង!!

ខ៖ ចាំ!!

ក៖ ប្រហែល៣៣ឆ្នាំហើយ!!!មីងការយូរដែរហើយ មីងកាលការអាយុប៉ុន្មានហើយមីង?

ខ៖ ការអាយុ២២។

ក៖ ២២ឆ្នាំ!!

ខ៖ ចាំ!!

ក៖ ហើយមានកូន៧នាក់ហ្នឹង?

ខ៖ ការហ្នឹងឪពុកចិញ្ចឹមខ្ញុំជាអ្នកអោយទេ ខ្ញុំអត់ស្រលាញ់ពេញចិត្តទេ តែគាត់ថាបើមិនយក គាត់ថាចាស់ៗពេលមុនគាត់ថានំមិនដែលធំជានាឡិទេអូនណាស់!!

ក៖ ចាំ!!

ខ៖ ញ៉ុមសុខចិត្តតាមគាត់!!!ខ្ញុំប្រកែកអត់យកដាច់ខាតហើយ!!ការហើយបានកន្លះខែ អត់បានកន្លះខែទេ ១២ថ្ងៃទេគាត់ដេញញ៉ុមចេញពីផ្ទះ។

ក៖ អ្នកណាគេដេញមីងចេញ?

ខ៖ ឪពុករបស់ខ្ញុំហ្នឹង!!

ក៖ ហ្ហ៎!!

ខ៖ គាត់ដេញខ្ញុំចេញពីផ្ទះ គាត់អត់អោយញ៉ុមយកប្តីហ្នឹងទេ!!

ក៖ ហាំ??

ខ៖ អោយខ្ញុំលែងចោលទៅ!!

ក៖ ពីដំបូងគាត់អ្នកបង្ខំអោយយក?

ខ៖ ចាំគាត់អ្នកអោយខ្ញុំយក ញ៉ុមប្រកែកអត់យក គាត់ថានំមិនដែលធំជាងនាឡិទេ ពេលខ្ញុំការហើយបាន១២ថ្ងៃហ្នឹងប្តីខ្ញុំគាត់លេងបាល់គាត់ខឹងប្តីខ្ញុំគាត់ដេរប្តីខ្ញុំ គាត់ដេញញ៉ុមចេញ គាត់ថាង៉ែងលែងចោលទៅចាំការអោយមួយទៀត!! ហើយខ្ញុំថាឪពិបាកស្រណុកអីខ្ញុំអត់មួយជាពីរអីទេ!! ព្រោះអីឪឯងអ្នកអោយខ្ញុំមិនមែនអ្នកជ្រើសរើសខ្លួនឯងទេ!!ញ៉ុមនិយាយអីចឹងណាស់!!

ក៖ ចាំ!!

ខ៖ បើសិនជាអោយញ៉ុមលែងខ្ញុំអត់លែងទេ ពីព្រោះអីពិបាកស្រណុកវេទនាចុះក៏ខ្ញុំតាមប្តីខ្ញុំដែរ គាត់ដេញខ្ញុំចេញពីផ្ទះ សូម្បីតែខ្ញុំការហើយស្បែកជើងខ្ញុំក៏គាត់អត់អោយដែរ ដង្កៀបបួងសក់ក៏គាត់អត់អោយខ្ញុំដែរ ខ្ញុំមានតែសំពត់កាញ់ចាស់មួយទេ សំពត់កាញ់ចាស់អាវចាស់មួយទេ ញ៉ុមចុះទៅតាមប្តីទៅដេកជាមួយម៉ែក្មេក គ្រែមួយ៤នាក់ ជីវិតញ៉ុមអូនអត់មានចានមួយអំបែងស្លាបព្រាមួយម៉ែចែកអោយទេ!!

ក៖ ចាំ!!

ខ៖ ហើយប្តីខ្ញុំគាត់ធ្វើទាហានមានតែមុងមួយខ្នើយមួយទេ!!

ក៖ ចាំ!!

ខ៖ ហើយរួចហើយខ្ញុំសន្យាជាមួយប្តីខ្ញុំអញ្ចឹងញ៉ុមថាខ្ញុំអត់ឯងក៏ខ្ញុំអត់មានយកអ្នកណាទៀតដែរ!!ទោះបីអត់មានកូនក៏ដោយក៏ខ្ញុំអត់មានយកអ្នកណាទៀតដែរ!!អីចឹងបានញ៉ុមនិយាយប្រាប់ឪពុកញ៉ុមថា ឪឯងចាំសំដីញ៉ុម ញ៉ុមអត់មានអោយអ្នកណាមកក្រលងខ្លួនខ្ញុំពីបីនាក់ទេមួយគឺមួយជីវិត អញ្ចឹងបានញ៉ុមប្រាប់ប្តីញ៉ុម អញ្ចឹងបានគាត់ឈ្លោះជាមួយខ្ញុំ ប្តីខ្ញុំគាត់ថាខ្ញុំនេះមានប្រុសទៀត!!ញ៉ុមថាឯងចាំសំដីខ្ញុំណាស់ ប្រុសឥឡូវនេះអ្នកណាក៏ខ្ញុំអត់យកដែរ ប្រហែលប្តីប្រពន្ធកំលោះក្រមុំនៅវេទនាអូនណាស់!!

ក៖ ចាំ!!

ខ៖ ចុះទំរាំតែយកគេអ្នកផ្សេងមក យើងស្គាល់ចរិកគេអត់!!

ក៖ ចាំ!!

ខ៖ យើងពិបាករបៀបម៉េចយើងចិញ្ចឹមកូននេះ!!គេតិះដៀលកូនរបៀបម៉េច!!

ក៖ ចាំ!!

ខ៖ គេដៀលកូនយើងរបៀបម៉េច ចុះអាប្រុសឥឡូវនេះយកមកយើងយកវាប៉ុណ្ណឹង ចុះបើធ្វើបាបកូនយើងទៅ យើងមើលម៉េចឃើញ!!អាឪចុងហ្នឹងណាស់!!

ក៖ ចាំ!!

ខ៖ បានថាញ៉ុមសុខចិត្តនៅជាមួយកូនអត់ស៊ីមានស៊ីកំលាំងខ្ញុំខ្ញុំនៅរករួចខ្ញុំនៅរក កំលាំងញ៉ុមដេកខ្ញុំដេក ខ្ញុំលាងចានតាមរោងការអូនរាល់ថ្ងៃណាស់!!ទឹមតែខានទេថៅកែគេលែងជួលក៏ខ្ញុំអត់ទៅ!!មួយរោងមកឆ្លៀតបង់អង្គការ ឆ្លៀតហូប!!កូនកូនរកធ្វើការមកគប់លុយបង់ ឥឡូវញ៉ុមជិតដាច់ហើយ!!

ក៖ ចាំ!!

ខ៖ នៅតែអង្គការនោះនៅ២៦០០០០អង្គការនេះនៅតែ៣០០(ដុល្លារ)ទៀតទេអស់ហើយ!!

ក៖ ចាំ!!ខ៖ ញ៉ុមរកសងគេបណ្តោះៗញ៉ុមឈប់យកហើយ!!ញើសឈាមខ្ញុំមានប៉ុន្មានខ្ញុំហូបប៉ុណ្ណឹង!!ឥឡូវបានកូនញ៉ុមត្រើសៗ ឥឡូវបានមីមួយនោះបានដល់ខែម្ចាស់គេវេរតាមវីងអោយមកខ្ញុំហើយទៅណាស់!!

ក៖ ចាំ!!

ខ៖ ចាំ!!

ក៖ កូនមីងទៅនៅម្នាក់ផ្សេងឆ្ងាយ នៅភ្នំពេញមីងហេ?

ខ៖ ចាំ!!នៅកន្លែងឯបឹងសាឡាង!!

ក៖ គាត់ធ្វើការអីគេមីង?

ខ៖ គាត់នៅធ្វើការគេតាមផ្ទះណាស់!!

ក៖ ចាំ!!

ខ៖ ថាធ្វើបាយទឹកអីផ្ទះសម្បែងគេទុកដាក់អីអីចឹងទៅណាស់!!!

កៈ ចា៎!!

ខៈ តែម្ចាស់ផ្ទះគេក៏ល្អដែរ!!គេក៏ល្អដែរ។

កៈ ម៉េចបានស្គាល់គេទៅធ្វើដល់ណោះវិញអ្នកមីង?

ខៈ ញ៉ុមរាប់អានបងមួយផ្ទះសំណាក់នៅផ្សារដើមមៀន គាត់រាប់អានញ៉ុមណាស់!!

កៈ ចា៎!!

ខៈ គាត់ជួលញ៉ុមទៅមើលអាម៉ាគាត់ហ្នឹងដល់ពេលគាត់រាប់អានគាត់អានិតញ៉ុមគាត់រាប់អានខ្ញុំដល់ជន្លងគាត់ហ្នឹងរកក្មេងហើយគាត់ក៏ទាក់ទងខ្ញុំហ្នឹងយកកូនញ៉ុមហ្នឹងទៅ!!

កៈ ចា៎!!!

ខៈ គាត់ថាបើពិបាកក៏គាត់អត់អោយយកទៅដែរ!!ថាបើស្រណុកបានគាត់អោយកូនខ្ញុំទៅបើពិបាកគាត់អត់អោយកូនខ្ញុំទៅទេ!!!គាត់អានិតខ្ញុំណាស់!!

កៈ ចា៎!!

ខៈ ទៅដំបូងវាបាន១០០(ដុល្លារ)ឥឡូវបាន១២០ហើយ!!

កៈ ចា៎!!

ខៈ និយាយទៅម្ចាស់ផ្ទះគេក៏ស្រលាញ់គាត់ដែរ។

កៈ ហើយអត់មានអ្នកជួយទំនុកបំរុងផ្សេងអីទេ?

ខៈ អត់មានទេអូនមានតែកូនទេ!!

កៈ ចា៎!!

ខៈ រាល់ថ្ងៃ ខ្ញុំអត់មានប្តីទីពឹងទេរាល់ថ្ងៃ ប្តីខ្ញុំនេះដូចអ្នកដទៃ!!

កៈ ចា៎!!

ខៈ ខ្ញុំអត់មានប្តីទីពឹងទេ!!!ប្តីដូចអ្នកដទៃហើយ បានកូនទេ!!!

កៈ មីងកាលពេលការមានថ្លៃជំនូនមានថ្លៃអីគេអោយដែរហោ?

ខៈ ចាំមានទេតើ កាលការហ្នឹងមានថ្លៃជំនូនហ្នឹង៥០០ ៥០០លុយខ្មែរយើងហ្នឹងណាស់!!

កៈ ហើយមីងកាលពេលរៀនហ្នឹងមានមិត្តភក្តិដែលជិតស្និតអត់អ្នកមីង?

ខៈ ខ្ញុំមានតែឥឡូវគេលែងរាប់អានខ្ញុំអស់ហើយ ខ្ញុំក្រអ្នូនអើយគេលែងរាប់ហើយ!!

កៈ គេសុទ្ធតែមានមានហោ?

ខៈ ចាំគេសុទ្ធតែមានមាន!!ខ្ញុំក្រគេលែងរាប់អស់ហើយ។

កៈ ចាំ!!

ខៈ យើងវាអត់នោះ!!

កៈ ចាំ!!

ខៈ គេមានហើយអញ្ចឹងគេរាប់អានយ៉ាងម៉េចបើគេមានខ្លាចញ៉ុមទៅរកគេ។

កៈ ចាំ!!គាត់នៅឯណាដែរមីងគាត់ឥឡូវ?

ខៈ គាត់នៅសៀមរាបឯលិចហ្នំ!!ចំការឯលិច តែគេមានប្តីគេទៅនៅភ្នំពេញអស់ហើយ!!

កៈ ចាំ ហើយមីងកាលពេលនៅក្មេងអីធ្លាប់លេងអីជាមួយគ្នាអត់អ្នកមីង?

ខៈ អត់ដែលលេងទេគ្រាន់តែថារាប់អានតែពេលទៅរៀន!!

កៈ ចាំ!!

ខៈ ទៅសាលាអញ្ចឹងទៅ បើថានិយាយខ្ញុំពេលនៅពីក្មេងខ្ញុំមិនដែលមានមិត្តភក្តិខ្ញុំមិនដែល បានទៅផ្ទះអ្នកណាផងហ្នឹង!!

កៈ ចាំ!!

ខៈ បើខ្ញុំមួយថ្ងៃមួយថ្ងៃការងារ១០០ជំពូកហ្នឹង!!

ក៖ ចាំ!!

ខ៖ មើលប្អូនផងមើលគោកផង ធ្វើស្រែផង អូនឯងគិតមើលមើល!!ដឹកអង្ករទៀតហើយចិញ្ចឹមជ្រូកទៀតហើយយើងមានពេលឯណាដើរផ្ទះគេ!!

ក៖ ចាំ!!

ខ៖ មានពួកម៉ាក់ណាដើរបានទេ ដើរទៅមើលល្ខោនអូនឯងអត់បានដើរកើត គាត់អត់អោយទៅទេ!!

ក៖ ចាំ!!

ខ៖ មួយថ្ងៃមួយថ្ងៃនៅតែផ្ទះហ្នឹង!!

ក៖ ចាំ!!

ខ៖ មើលកូនគាត់ហើយគាត់រ៉ៃយើងទៀតណាស់!! តែនេះខ្ញុំថាខ្ញុំអត់ភ្លេចគុណគាត់ដោយសារអីដោយសារគាត់ចិញ្ចឹមយើងពីនោះមកដល់នេះ!!

ក៖ ចាំ!!

ខ៖ យើងរស់រានមានជីវិតក៏ដោយសារមានគាត់ចិញ្ចឹមដែរ!!

ក៖ ចាំ!!

ខ៖ ខ្ញុំគិតថាសងគុណគាត់ភ្លេចមិនបានទេព្រោះគាត់ចិញ្ចឹមយើងមែនយើងធ្វើបាបយើងមែនប៉ុន្តែគាត់ចិញ្ចឹម!!

ក៖ ចាំ!!

ខ៖ ពីទូចមកដល់នេះ!!យើងមានជីវិតរស់នៅក៏ដោយសារគាត់ដែរណាស់!!

ក៖ ចាំ!!

ខ៖ បានខ្ញុំចេះតែថានៅតែដឹងគុណគាត់អញ្ចឹងទៅ!!

កៈ ហើយពេលនៅក្មេងអត់បានដើរលេងអីជាមួយក្មេងៗផ្សេងៗអី?

ខៈ អត់ទេអូន អត់ទេ អូនឯងមិនជឿនេះទៅសួរយាយនេះ គាត់ចាស់ពេលមុនសួរទៅ ថាជីវិតខ្ញុំវេទនាពិបាករបៀបម៉េច!!!សួរគាត់ទៅបើគាត់មិននិយាយប្រាប់អស់!!

កៈ អត់ដែលមានបានសប្បាយសោះហើយមីង?

ខៈ អត់ទេ!!ខ្ញុំអត់ដែលបានទៅស្គាល់ទៅបុណ្យទៅទានឯណាសោះ!!

កៈ ចុះមីងអត់ដែលបានទៅមើលដូចថាល្ខោនតាមវត្តតាមអីៗ?

ខៈ អត់ទេអូន!!អត់បានទៅទេព្រោះអីទៅអត់បានទេ!!យប់ឡើងអូនឯងញ៉ុមប្រាប់ការងារខ្ញុំណាស់ម៉ោង៣លើកវែកអាចមន៍គោដាក់ស្រែ ភ្លឺម៉ោង៥ញ៉ុមភ្ជួរស្រែ រាយកណ្តាប់អោយគេ ញ៉ុមភ្ជួររើយណាស់!!

កៈ ចាំ!!

ខៈ រៀបកណ្តាប់អោយគេ!!ហើយម៉ោង១១ដាំបាយមើលប្អូន!!

កៈ ចាំ!!

ខៈ ម៉ោង១១ដាំបាយមើលប្អូនទៅឃ្វាលគោ មកពីឃ្វាលគោវិញដាក់បាយជ្រូក ដាំបាយហូបហើយចិញ្ចឹមប្អូនទៀតណាស់ ហើយគាត់ដេកតែនៅលើកន្ទេលទេ ម៉ែចិញ្ចឹមញ៉ុមណាស់!!

កៈ ចាំ!!

ខៈ ម៉ោងដល់ពេលហូបបាយហើយម៉ោង៧ ទៅម៉ោង៨ញ៉ុមបោកស្រូវ បុកស្រូវដល់ម៉ោង១២បានញ៉ុមបានដេក។

កៈ អត់មានសំរាកអីបន្តិចសោះ?

ខៈ ចាំ!!!បុកស្រូវក្នុងមួយយប់ទល់ភ្លឺញ៉ុមដេកបានតែ២ម៉ោងទេ!! ញ៉ុមប្រាប់អូនឯងត្រង់និយាយថាខ្ញុំ ខ្ញុំមិនមែនអួតតែខ្លួនខ្ញុំទេ ការងារមួយជីវិតគឺឆ្អែត មួយជីវិតស្ត្រីគឺខ្ញុំឆ្អែតហើយ!!ញ៉ុមឆ្អែតទាំងអស់អូន មួយជីវិតស្ត្រី អីចឹងបានញ៉ុម អីចឹងបានញ៉ុមទៅ និយាយទៅញ៉ុមជឿងទាំងអស់ ញ៉ុមជឿយេស៊ូវណាស់!!

កៈ ហ្ហ៎មីងជឿដែរ?

ខៈ ចាំពេលញ៉ុមចុះទៅសិក្ខាសាលា តាមួយហ្នឹងគាត់ថាញ៉ុមហ្នឹងជាស្ត្រីពេញលក្ខណៈមិនមែនស្រីទេ ព្រោះអីខ្សែរលកជីវិតខ្ញុំគឺឆ្អែតគ្រប់បែបយ៉ាងខ្ញុំឆ្អែតហើយ!!សូម្បីតែឯកឧត្តមនោះគាត់ទៅក៏គាត់សរសើរខ្ញុំចិញ្ចឹមកូន៧រស់!!ប្តីដើរតែផឹក អ្នកផ្សេងចិញ្ចឹមអត់រស់ទេ ញ៉ុមប្រាប់អូនឯងណាស់នេះឆ្អឹងជំនីរពីរហិ!!ខ្ញុំទៅមានតែលុយ៥០០០ខ្មែរទេ!! ខ្ញុំឈឺដេកពេទ្យជ័យជំនះមួយខែ ចេញមកវិញកូនជិះកង់បុកឆ្អឹងជំនីរពីរប៉ោងប៉ុនក្បាលជង្គង់ហ្នឹងហ៎!! ខ្ញុំចេញពីពេទ្យខ្លួនឯងបានមួយខែខ្ញុំឈឺណាស់!!ខ្ញុំគ្រុនពោះវៀន៣២០ខ្ញុំថាខ្ញុំមិនរស់ផង ជីវិតខ្ញុំហេ ចេញមកផ្ទះគាត់យកទៅវះទៀតវះនៅដល់ឈាមហូរអត់ឈប់ ឈាមហូរពេញទាំងអស់ពុកឆ្អឹងជំនីរពេញ។

កៈ នៅក្មេងសោះពុកឆ្អឹងមីងណោះ?

ខៈ វាបុកដៃកង់មិនដឹងតាំងពីខែណាមក!!

កៈ ហ៎ុ!!

ខៈ ហើយដល់ពេលហើយខ្ញុំយកកូនទៅវះសង្គ្រោះបន្ទាន់ ខ្ញុំកាន់កន្ត្រកញរ័ញ៉េរទៅដេកពេទ្យកូនមួយហ្នឹងហ៎!!មានលុយតែ៥០០០ទេហើយដល់ហើយអ្នកជិតខាងញ៉ុមគេចេះតែអោយអ្នកជិតខាង ១០០០០ ២០០០០ ៣០០០០ គេអោយទៅណាស់ !!

កៈ ចាំ!!

ខៈ ដល់ខ្ញុំនឿយពេក លុយហ្នឹងញ៉ុមបានអោយកូនដេកទៅណាស់ ដល់ខ្ញុំខ្ញុំហូបតែបបរទេមួយពេលញ៉ុមហូបតែបបរតែ១០០០ទេ បបរមួយវែកហ្នឹងហ៎!!ខ្ញុំសុខចិត្តទុកអោយកូនណាស់!!
កៈ ចាំ!!

ខៈ ដល់ពេលថ្ងៃមួយអូនអើយអស់លុយហើយលុយដែលគេជួយទៅហ្នឹងបាន៤ថ្ងៃវះកាត់បាន៤ថ្ងៃ ដល់វះកាត់ដំបូង ទៅដល់វះកាត់ភ្លាម ខ្ញុំនិយាយវះកាត់ភ្លាម អង្គការហ្នឹងគេតែរកអ្នកផ្តល់ឈាម ញ៉ុមថាញ៉ុមអត់មានសាច់ញាតិសន្តានទេ លោកគ្រូអើយញ៉ុមមានតែឯងទេស្រីក៏ខ្ញុំប្រុសក៏ខ្ញុំដែរ អត់មានអ្នកណាទៅទាំងអស់ប្រាប់អូនឯង!!កូនខ្ញុំនេះគេជួយ មីមួយមិញហ្នឹង អូនឯងដឹងម៉េចទេទៅដល់ពេទ្យគន្ធបុប្ផាគេរកអ្នកផ្តល់ឈាមអត់អត់ស្រាប់តែតាមហ្នឹងក៏អង្គការក៏គេជួយផ្តល់ឈាមកូនខ្ញុំហ្នឹងហ៎ គេជួយខ្ញុំណាស់!!

ក៖ ចាំ!!

ខ៖ ដល់ពេលលុយគេអោយទៅខ្ញុំបាន៣ថ្ងៃ ៣ថ្ងៃអូនឯងគិតមើល ថ្ងៃមួយញ៉ុមអស់លុយ ហើយសល់តែ៧០០០ខ្មែរទេ!!ខ្ញុំអត់ដឹងទៅណាទេ ហើយណាមួយខ្ញុំក៏ធ្វើទុក្ខ លុយអស់ទៀត!!!!អូនណាស់ញ៉ុមធ្វើទុក្ខមែនទែន ញ៉ុមញ៉ុមសឹងផុតដៃគេ ញ៉ុមសុខចិត្តទុកកូនចោល ម៉ោង៦យប់ហ៊ិខ្ញុំដើរទៅខាងលិចពាក់កណ្ដាលគន្ធបុប្ផាហ្នឹង ខ្ញុំចុះចុះអគារបីជាន់ហ្នឹងអូនឯង គិតមើល ខ្ញុំដើរអូនអើយថាជីវិតខ្ញុំប្រហែលជាអត់បានជួបកូនវិញទេ ញ៉ុមដើរទៅអូនឯងគិត មើលសន្លប់គៀនពេទ្យហ្នឹង!!ខ្ញុំអត់ដឹងខ្លួន ញ៉ុមទៅដល់កន្លែងទិញថ្នាំពេទ្យហ្នឹងខ្ញុំសន្លប់។

ក៖ ហើយអ្នកណាគេមើលកូនមើលអីទៅអ្នកមីង?

ខ៖ កូនដេកខ្ញុំផ្ញើរគេជិតខាងហ្នឹង!! ទៅដល់ខ្ញុំសន្លប់គៀនពេទ្យហ្នឹង ពេទ្យ ពេទ្យគេលក់ថ្នាំ ហ្វាម៉ាស៊ីហ្នឹងគេក៏ស្ទុះមក ស្ទុះមកមើលខ្ញុំ ដល់ពេលខ្ញុំដឹងខ្លួនគេសួរខ្ញុំថាថី?ញ៉ុមថាញ៉ុមដើរមក ទិញថ្នាំដល់ហើយខ្ញុំដួល បានគេអោយបាយហូបគេអោយទឹក អីអីហូបហ្នឹងមានកំលាំង ក៏គេ លក់ថ្នាំហ្នឹង៣០០០០ហ្នឹងក៏គេអត់យកលុយទៀត!!ញ៉ុមបានថ្នាំហ្នឹងញ៉ុមលេបរហូតញ៉ុមបានកំ លាំងញ៉ុមមើលកូនហ្នឹង!!ទាល់តែកូនញ៉ុម ដល់តែថ្ងៃញ៉ុមអត់លុយ មានលុយព្រឹកឡើងមាន លុយតែ៧០០០ខ្ញុំមិនដឹងធ្វើម៉េចទេ!!ក៏ទិញបាយអោយកូនមួយពេលសិន គិតហើយណាស់!!

ក៖ ចាំ!!

ខ៖ ទិញបាយអោយកូនមួយពេលសិន ម៉េចម៉េចចាំសុំបាយមន្ទីរពេទ្យចាំសុំបាយ ដល់ហើយ ស្រាប់ម៉េចអូនឯងអានេះដូចថបុណ្យផលយើងមកដល់អញ្ចឹងទៅណាស់!!

ក៖ ចាំ!!

ខ៖ ស្រាប់តែអង្គការមក ស្រាប់តែខ្ញុំអង្គុយយំអញ្ចឹងហ៊ិ គេមកឃើញខ្ញុំអង្គុយយំ ពេទ្យស្គាល់ហ្នឹង ក៏គាត់ទៅប្រាប់ដុកទ័រហ្នឹងហើយគាត់ហៅខ្ញុំសួរថាអ៊ី អ៊ីឯងយំថី?អត់មានអីអោយកូនហូបទេ អត់មានលុយទិញបាយអោយកូនហូប ហើយស្មើរហ្នឹងហើយកូនឃ្លាន ហើយមិនដឹងយ៉ាង ម៉េចស្រាប់តែអង្គការគេមក អូនឯងមើលស្រាប់តែអង្គការមកគេហៅខ្ញុំទៅផ្ដិតមេដៃ មួយ អាទិត្យ៧០០០០!!

ក៖ ហ៊ឺ!!

ខ៖ គេបើកអោយមួយអាទិត្យមួយអាទិត្យតែម្តង!!ខ្ញុំបានខ្ញុំអរអើយអរដូចកើតម្តងទៀតអូនអើយ បានមើលកូនហ្នឹងបានមួយខែបានចេញមកផ្ទះបានញ៉ុមសល់លុយហ្នឹងបានជាង១០០០០០!!

ក៖ ចាំ!!

ខ៖ ញ៉ុមសល់លុយ១៤០០០០ហាំ!!មកផ្ទះហាំ!!

ក៖ ចាំ!!

ខ៖ ញ៉ុមដើរទិញអង្ករណៃ កូនឡើងរញ៉ុងនៅផ្ទះញ៉ុមប្រាប់ទៅ។

ក៖ ហើយអត់មានអ្នកណាគេនៅផ្ទះ?

ខ៖ មីមួយនេះទឹមតែបាន៤ខែទេហិ!!!

ក៖ អូយបានអ្នកណាគេអ្នកមើលទៅអ្នកមីង?

ខ៖ មីបងមីបងមានកូនហ្នឹង!!

ក៖ ចាំ!!

ខ៖ គ្នាធ្វើគ្រូអង្គការ បង្រៀនមួយថ្ងៃ២ថ្ងៃបានតែ៤០រៀលទេ!!

ក៖ ចាំ!!

ខ៖ មួយខែបានតែ៤០រៀលទេ!!

ក៖ ចាំ!!

ខ៖ មួយថ្ងៃបង្រៀនពីរថ្នាក់ រត់ទៅបង្រៀនហើយរត់មកមើលប្អូន បញ្ចុកបាយប្អូនយប់ឡើងអត់បានដេកទេ!!នៅមើលប្អូន។

ក៖ បង្រៀនដល់ណាទៅអ្នកមីង?

ខ៖ បង្រៀននេះសាលាត្បូងនេះ!!!សាលាអង្គការដើមត្នោតយើងខាងលិចហ្នឹង!!!

កៈ ចាំ!!

ខៈ គេយកដាក់អោយរៀននៅទីហ្នឹង!!!

កៈ សាលាហ្នឹងជាអង្គការខាងអីគេមីង?

ខៈ អង្គការមនុស្សលោកថ្មីខាងបញ្ចុកបបរកូនក្មេងអញ្ចឹងទៅណាស់!

កៈ ហ្ន៎!!

ខៈ បង្រៀនក្មេងធ្វើអីផាត់រូបអីធ្វើអី វាធ្វើគ្រូបង្រៀននៅទីហ្នឹង!!

កៈ ចាំ!!

ខៈ ចាំវាចេះតែមើលប្អូនទៅខ្ញុំដេកពេទ្យគន្ធបុប្ផាហ្នឹងមួយខែ នៅមើលអាមួយហ្នឹង!!

កៈ ចាំ!!!

ខៈ ថាខ្ញុំវេទនាណាស់អូនអើយ!!

កៈ ចុះថាអង្គការអីគេហ្នឹងជួយមីងនោះ?

ខៈ ញ៉ុមអត់ដឹងអង្គការអី!!

កៈ ស្រាប់តែគេនាំមកអោយអញ្ចឹងតែម្តង?

ខៈ ចាំគេនាំអោយផ្តិតមេដៃយកលុយ ញ៉ុមអត់ដឹងដែរ!!

កៈ ហ៊ឺ!!

ខៈ ហើយគេប្រាប់ទៀតណាស់កុំអោយប្រាប់អ្នកជិតខាងណាស់កុំអោយគេដឹង ព្រោះគេសុទ្ធតែអត់ដែរ ប៉ុន្តែមិនមែនអត់ដូចមីងឯងពេក!! គាត់និយាយអ៊ិចឹងណាស់!!

កៈ ចាំ!!

ខៈ ចេះបានលុយហ្នឹងមក!!

កៈ ហើយគេជួយមីងបានប៉ុន្មានឆ្នាំដែរមីងឬក៏ប៉ុន្មានខែ?

ខៈ អត់ទេជួយបានតែមួយដេកយើងចេញពីពេទ្យហ្នឹង!!!

កៈ ចាំហ្ន៎!!

ខៈ គេជួយតែប៉ុណ្ណឹងទេតើ!!

កៈ ចាំចេះបានមានគេជួយដែរ!!!

ខៈ ចាំហើយឈាមអីគេផ្តល់អោយហ្នឹង ខ្ញុំអត់ដឹងដែរ ខ្ញុំអត់ឃើញគេទារលុយទារអីផង!!

កៈ ចាំ!!

ខៈ គេផ្តល់ឈាមអោយកូនហ្នឹង!!

កៈ នៅពេទ្យគន្ធបុប្ផាហ្នឹងមែន?

ខៈ ចាំ!!

កៈ ចាំ!!ពេទ្យហ្នឹងគេអត់យកលុយទេពេទ្យហ្នឹងនោះ!!!

ខៈ ខ្ញុំអត់ដឹងដែរ មិនដឹងខាងណាខ្ញុំអត់ដឹងដែរ!!

កៈ ចាំ!!

ខៈ ដល់ពេលពេទ្យថាហ៊ីអ្នកមីងមានអ្នកផ្តល់ឈាមអោយកូនអ្នកមីងហើយអ្នកមីងមិនបាច់ភ័យទេ!!

កៈ ហ៊ីសំណាងណាស់អ្នកមីង!!

ខៈ បានខ្ញុំអរគុណអើយ!!បានខ្ញុំចេះអត់អី បានខ្ញុំថាប្រវត្តិរបស់ខ្ញុំប្រវត្តិជូរចត់ បានខ្ញុំសួរក្មេងរាល់ថ្ងៃ បានដឹងថារាល់ថ្ងៃមានរសជាតិមានប៉ុន្មានយ៉ាងមានដឹងទេ!!វាអត់ដឹងទេ ប៉ុន្មានយ៉ាងក៏វាអត់ដឹងដែរ!!ខ្ញុំថាហ្នឹងហើយជីវិតមនុស្សនោះ ជូរចត់មានជូរមានចត់មានផ្អែម មានក្តៅមានត្រជាក់!!

កៈ ចាំ!!

ខៈ អោយគិតមើលអញ្ចឹងបានថាក្មេងឥឡូវម៉ែឪខ្លះមានលុយអោយកូនរៀនហើយកូនអត់រៀនទៀតអត់ខំទេ កូនដើរអាលាតែ ទៅណេះទៅណោះ!!

កៈ កូនមីងស្រួលៗដែរ អ្នកមីងអ្នកណាគេពិបាកទេអត់អីទេមីង ?

ខៈ ចាំ!!អត់អីទេអូនកូនញ៉ុមនេះគឺវាដឹងម៉ែដឹងឪពេលខ្ញុំឈឺអឺចឹង វាធ្វើការវាចេញវាទិញនេះទិញនោះយកមកអោយ!!

កៈ ចាំ!!

ខៈ ហើយអាមួយថ្នាក់ទី១២ញ៉ុមឃើញអាមួយហ្នឹងអង្គុយជូតទឹកភ្នែកអោយ ប្រុសទេណាស់ និយាយឥឡូវញ៉ុមធូរបន្តិចអូន។

កៈ កូនបានអីជិះទៅរៀនទៅមីង?

ខៈ កូនញ៉ុមជិះកង់តាំងពីថ្នាក់ទី៧ហ្នុំ!!!

កៈ ចាំ!!

ខៈ ហើយពេលមុនគាត់រៀននៅទីនេះថ្នាក់ទី៦!!ដល់ឡើងទៅលើបងថ្លៃអោយកង់មួយ ជិះកង់តាំងពីថ្នាក់ទី៧ដល់ថ្នាក់ទី១២។

កៈ ចាំ!!

ខៈ ជិះតែកង់!!

កៈ ជិះឆ្នាំប្រលង!!

ខៈ ចាំ!!

កៈ ជិតដល់ពេលប្រលងហើយ!!!

ខ៖ គាត់ជិះគាត់ជិះតែកង់ហ្នឹង ហើយដល់ពេលគាត់ឈឺ យើងឈប់ ឈឺយើងឈប់ស្រាប់តែអានាយកសាលាគេដាក់សំបុត្រអោយខ្ញុំទៅ ហើយបានកូនឈប់អញ្ចឹងគេសង្ស័យអញ្ចឹងទៅណាស់!!

ក៖ ចាំ!!!

ខ៖ ព្រោះអីវាមើលទៅវាស្គម ព្រោះអីខ្លាចថាវាលេងថ្នាំលេងអីអញ្ចឹងទៅគេសង្ស័យ កូនខ្ញុំវាគ្រុនពោះវៀននោះ!!

ក៖ ចាំ!»!

ខ៖ ហើយខ្ញុំថាអត់ទេ កូនខ្ញុំកង់ខូចហើយវាគ្រុនពោះវៀន!!ហើយខ្ញុំអត់មានលុយប៉ះកង់ប៉ះអីអញ្ចឹងណាស់!!!

ក៖ ចាំ!!

ខ៖ អញ្ចឹងនាយកសាលាគាត់ថាខ្ញុំហ្នឹងនៅទំនប់៩៨ហ្នឹងទៅពិបាកណាស់តែពេលមេឃភ្លៀងមេឃអី!!

ក៖ ចាំ!!

ខ៖ ហើយបានគ្រូថ្នាក់វាហ្នឹងបានថាគាត់ធានាថាពិសាលគាត់អត់អីទេ!!គាត់ធានាសិស្សមួយហ្នឹងគាត់និយាយអញ្ចឹងណាស់!!

ក៖ ចាំ!

ខ៖ កូនញ៉ុមពេលមុនដងតើអ្នកមីងគាត់ជួយណាស់!!អោយដេកនៅហ្នឹងហូបនៅហ្នឹងទៅ!!តែលើរៀនអីលើយើងបាយទឹកផ្ទះដេកអីហ្នឹងគាត់ជួយ។

ក៖ មានអ្នកជួយដែរ!!

ខ៖ ចាំអ្នកគ្រូហ្នឹងគាត់ជួយ គាត់ថាហ្នឹងឥឡូវគាត់ជួយ ត្រឹមថ្នាក់ទី១០គាត់លែងជួយហើយ!!

ក៖ ចាំ!!

ខ៖ ថ្នាក់ទី១១ញ៉ុមធ្វើការនៅផ្ទះគយ គយផ្ទះតាយុន សារុននៅជាប់វត្តព្រៃកប្ញស្សីអ៊ិចឹងខាងជើងហ្នឹងមិនផ្ទះហ្នឹង ហើយញ៉ុមធ្វើការនៅទីហ្នឹង!!!ញ៉ុមយកលុយអោយកូនរៀន ទំរាំកូនបានចប់ថ្នាក់ទី១១ញ៉ុមចង់លូនហើយញ៉ុមប្រាប់អូនឯងទៅ!!!អោយតែថ្ងៃចន្ទ័អោយតែថ្ងៃអាទិត្យរាប់លុយទុកអោយកូនអោយទៅរៀនហើយ!!

ក៖ ចាំ!!

ខ៖ មួយអាទិត្យ៦០០០០!!វាហូបអីនៅហ្នឹង!!

ក៖ ចាំ!!

ខ៖ ជូនកាលវាហូបនំប៉ុងមួយអូនណាស់ មួយថ្ងៃអូនណាស់!!!បែកកង់បែកអីៗថាជីវិតរបស់ខ្ញុំវេទនាណាស់អូនអើយ!!

ក៖ ហើយមីងតាំងពីតូចមកមានដែលធ្លាប់គិតថាមានភាពជោគជ័យលើអីគេមួយអត់មីង?ដូចថាកិច្ចការមួយដែលមីងធ្លាប់ជោគជ័យអី?

ខ៖ អើរមាន!!ញ៉ុមអើរដូចថាញ៉ុមមាន ញ៉ុមមានធ្លាប់ជោគជ័យអញ្ចេះ ញ៉ុមទៅធ្វើការ អាហ្នឹងញ៉ុមពិបាកហើយបានខ្ញុំមានជោគជ័យណាស់!!

ក៖ ចាំ!!

ខ៖ ខ្ញុំកូនខ្ញុំនៅទូចទូចអញ្ចឹងហិ ខ្ញុំទៅធ្វើការចោលកកូនហិ ទៅដេកផ្ទះគេនៅតាខ្មៅហ្នំ!!បើយើងទៅមកយើងអត់អីជិះ!!

ក៖ ចាំ!!

ខ៖ បើយើងអត់ធ្វើកូនអត់អីហូប!!

ក៖ ចាំ!!

ខ៖ ញ៉ុមសុខចិត្តចោលកូនរញ៉ុងណាស់ ចុះកាលហ្នឹងខ្ញុំផ្ទះស្លឹក២ខ្នង់តូចដែរទេ ដល់ពេលមីមួយនេះវាដំាបាយហ្នំ!!វាពន្លត់អុសអត់អស់មិនឆេះផ្ទះអស់!!

ក៖ ហ៊ឺ!!!!

ខ៖ ញ៉ុមឆេះផ្ទះអស់រលីងណាស់!!

ក៖ ចាំ!!

ខ៖ ឆេះអស់ទាំងអស់!!ហើយខ្ញុំអត់មានសល់អីទេកូនចៅខ្ញុំសល់ឡើងមួយរ៉ូងសល់តែមួយ ចង្កេះទេឆេះអស់រលីង ដល់ពេលហើយគ្រាន់តែឆេះអស់ភ្លាម ព្រោះអីខ្ញុំជឿលើព្រះអង្គខ្ញុំជឿ លើយេស៊ូវណាស់!!

ក៖ ចាំ!!

ខ៖ ខ្ញុំឆេះផ្ទះអស់ញ៉ុមមកផ្ទះញ៉ុមឃើញញ៉ុមឃំញ៉ុមអត់មានអីសង្ឃឹមទៀតទេបើមកដល់ផ្ទះ អត់មានអីជ្រក បើរាល់ថ្ងៃវាជីវភាពវាខ្វះខាត ជីវភាពយើងបានព្រឹកខ្វះល្ងាចណាស់!!

ក៖ ចាំ!!

ខ៖ ដល់ពេលហើយប្អូនខ្ញុំវាធ្វើគ្រូបង្រៀនហ្នឹងក៏វាប្រាប់ថាបងមិនបាច់ភ័យទេ ឆេះអោយអស់ ចុះ!!ទ្រព្យយើងនៅមានទៀតឆេះអស់ប៉ុណ្ណឹង!!គាត់ថាដង្វាយព្រះអង្គរៀបចំទុកអោយហើយ ហើយ គាត់និយាយណែនាំញ៉ុមអញ្ចឹងណាស់!!

ក៖ ចាំ!!

ខ៖ គាត់ថាបងចាំតែនៅចុះ!!ហ្នឹងផ្ទះហ្នឹង!!

ក៖ គេធ្វើអោយ។

ខ៖ បងចាំតែនៅចុះបងមិនបាច់ពិបាកទេ!!!គេជួលជាងគេជួលអីអោយមួយចប់!!អញ្ចឹងបានខ្ញុំ ថាខ្ញុំអរគុណព្រះអង្គដែរ ដែលប្អូនញ៉ុមដឹកនាំខ្ញុំបានជោគជ័យកន្លែងហ្នឹង!!

ក៖ ចាំ!!

ខ៖ ចាំគេជួយញ៉ុមបានជោគជ័យនៅដល់រាល់ថ្ងៃគឺដំបូលរបស់ព្រះអង្គ ញ៉ុមនិយាយត្រង់។

ក៖ ល្អណាស់អ្នកមីងបានស្គាល់ព្រះយេស៊ូវគ្រីស្ទញ៉ុមខ្លួនឯងញ៉ុមអត់លាក់បាំងគឺខ្ញុំជាអ្នកជឿ លើព្រះយេស៊ូវគ្រីស្ទ!!

ខ៖ ចា៎!!

ក៖ ញ៉ុមជឿខ្លាំងមែនទែនតែម្តង ដោយសារពេលមុនគ្រួសាររបស់ខ្ញុំក៏ពិបាកដែរ ដោយសារតាំងពីញ៉ុមចូលសាសនាគ្រីស្ទមកគឺគ្រួសារខ្ញុំរីកចំរើនខ្លាំងមែនទែន។

ខ៖ កូនខ្ញុំអារៀនហ្នឹងក៏វាជឿព្រះអង្គដែរ!!

ក៖ ចា៎ អញ្ចឹងបានថាញ៉ុមមានអារម្មណ៍ហើយញ៉ុមសប្បាយចិត្តថាញ៉ុមអរគុណខ្លាំងមែនទែនដែលខ្ញុំបា៎នស្គាល់!!

ខ៖ ចា៎!!

ក៖ ពេលមុនគ្រួសាររបស់ខ្ញុំពិបាកវេទនាដែរ ហើយពេលដែលញ៉ុមបានចូលបានស្គាល់សាសនាគ្រីស្ទមកមឹងថាគ្រួសារញ៉ុមរីកចំរើនហើយគ្រួសារពួកខ្ញុំមានសុភមង្គលទៀត!!

ខ៖ ចា៎អ៊ីចឹងបានខ្ញុំថាខ្ញុំអរគុណព្រះអង្គ ការអស្ចារ្យហ្នឹងមួយគឺផ្ទះហ្នឹងតែម្តង!!

ក៖ ចា៎!!

ខ៖ ញ៉ុមធ្លាប់អធិស្ឋានហា!!អធិស្ឋានកាលពេលផ្ទះញ៉ុមមុនផ្ទះស្លឹកញ៉ុមអត់ ភ្លៀងមកអញ្ចឹងអូនអើយលិចទាញកៅស៊ូប្រកអានេះប្រកអានោះ!!

ក៖ ចា៎!!

ខ៖ ដល់តែពេលហើយញ៉ុមដេកអធិស្ឋានរហូតរាល់យប់ថាព្រះអង្គអើយថ្ងៃណាបានដំបូលសង្ក័សីភ្លៀងអ៊ីចឹងមកបានកូនដេកអោយគេលក់ស្កប់ស្កល់ កុំអោយពិបាក ចេះតែអធិស្ឋានសុំរហូត សុំស្រាប់ដល់តែថ្ងៃមួយដេកយល់សប្តិវាថាប្អូនញ៉ុមគ្រូបង្រៀនហ្នឹង ថាស្រាប់តែថាហ៊ីហៅខ្ញុំមកបងមកទៅនៅជាមួយខ្ញុំ មកបានមានក្តីសុខសាន្តអត់មានអើរ អត់មានពិបាកទេបង!! ខ្ញុំក៏មើលឃើញទៅឃើញផ្ទះក្បឿងឡើងខ្ពស់ត្រដែតនៅលើទួល វាហៅខ្ញុំទៅមិនបាច់យកស្អីមកទេ!!នាំតែកូនមក ខ្វះអីទេទ្រព្យសម្បត្តិហ្វា៎!!ញ៉ុមព្រលឹងនាំកូន អូនអើរញ៉ុមធ្វើការនៅកន្លែងកាប៉ាស់សាំងដរវត្តចំពុះភ្អែកហ្នឹងម៉ោង១១ញ៉ុមអង្គុយបត់ខោអាវអោយគេ គេអត់ទាន់ដេកទេណាស់!!

ក៖ ចា៎!!

ខ៖ បត់ខោអាវគេដាក់ក្នុងកន្ត្រក់តែគេក៏ជិតផមិដែរ អាប្អូនញ៉ុមតេទៅរ៉ឹងថាផ្ទះញ៉ុមឆេះអស់ហើយ គ្រាន់តែញ៉ុមយល់សប្តិប៉ុណ្ណឹងភ្លាមផ្ទះញ៉ុមឆេះអស់ដែរ!!អូនឯងគិតមើលមើលធ្វើការអស្ចារ្យទេ!!!

ក៖ ចាំ!!!

ខ៖ ដល់ពេលហើយស្រាប់ដល់ហើយក៏ម្ចាស់ផ្ទះហ្នឹងហិប្រាប់ញ៉ុមថាភ្លើងឆេះផ្ទះទៀត គាត់ជំនុំ៣នាក់កូនគាត់ណោះក្រោមហ្នំអត់អោយញ៉ុមដឹងទេ ហើយខ្ញុំចេះតែឆ្ងល់២នាក់ហ្នឹងនិយាយមើលមុខខ្ញុំហើយមីកូនឈ្មោះអាណែតហ្នឹងវាថាអ៊ឹងឯងបត់ខោអាវបត់តែខោអាវទៅ វាចេះតែប្រាប់ញ៉ុមអញ្ចឹងណាស់!!ស្រាប់តែព្រឹកឡើងត្រូវស្អែកហ្នឹងខ្ញុំទៅផ្ទះបត់ខោអាវគេហើយហើយស្អែកឡើងខ្ញុំត្រូវមកផ្ទះមកមើលកូនមើលចៅ ព្រោះថ្ងៃអាទិត្យខ្ញុំមកម្តងណាស់!!!

ក៖ ចាំ!!

ខ៖ ស្រាប់តែដល់ពេលព្រឹកឡើងអ៊ំរៀបចំអីវ៉ាន់ទៅ ហើយជិតមាយចិនហ្នឹងខ្ញុំថាគេតិចអៀរមាយចិនហ្នឹងអោយអីវ៉ាន់ហ្នឹង អត់ដឹងទេ គេមានប្រាប់ថាខ្ញុំឆេះផ្ទះឯណា!!!តាំងពីអង្ករមួយបេប្រហុក អំបិល ប៊ីចេងអី ប្រេងឆា ចាន ឆ្នាំង កំបិតអី ខោអាវអីលែងម៉ាអាកង់បីឡើងពៀព ហៅកង់៣គេដាក់ថាចំអាណែតហ្អែងអោយអីវ៉ាន់ច្រើនម្ល៉េះ?និយាយបងអោយអីវ៉ាន់ច្រើនម្ល៉េះ?ថាទៅយកទៅផ្ទះទៅ ហើយគេអោយលុយ៥០០០០ទៀត!!ដល់ពេលហើយញ៉ុមមានដឹងឯណាគេអោយលុយ៥០០០០ទៀតញ៉ុមគេដេញទៅផ្ទះទៅញ៉ុម!!អ៊ឹងឯងទៅផ្ទះចុះ អីវ៉ាន់ញ៉ុមរៀបដាក់អីហើយអស់ហើយអីមួយចប់ហើយ!!អត់ដឹងថាម៉េចទេ ញ៉ុមក៏ឡើងកង់បីមកតាមគេ ប្រាប់កង់៣គេថាពូដឹកគាត់អោយដល់៩៤ណាស់!!គាត់ដល់ព្រែកហូរណាស់ ប្រាប់ពូកង់៣ពូឈប់សិនញ៉ុមទិញម្ហូបអោយកូនញ៉ូមក៏ចុះទៅទិញម្ហូបអោយកូន ហើយខ្ញុំក៏ទិញត្រីយកមកស្លរ ចុះទៅមិនទាន់បានទិញផងចុះពីលើអាកង់៣ទទួលអាប្រុសវានៅហ្នឹងដែរ មីងផ្ទះមីងឯងឆេះអស់ហើយ!!ហ្អែងចេះតែថាម៉ងហាំអានេះហាំ!!ហ៊ឺមីងញ៉ុមប្រាប់អត់ជឿ ឆេះអស់ហើយហ្នឹងណាស់មីងឯងមើលជើងញ៉ុមហិ មុតដែកគោលយប់មិញខ្ញុំពន្លត់ហ្វំ!! មីងឯងសំណាងហើយកូនអត់នៅបើកូននៅឆេះអស់។

ក៖ ហ៊ឺហើយចុះកូនទៅណាមីង?

ខ៖ វាដាំហើយវានាំគ្នាទៅមើលធុងបាស គេចាក់ធុងបាសរាំវាមិននាំគ្នាទៅលេង!!

កៈ ចាំ!!

ខៈ ជិតចូលឆ្នាំហើយហ្នឹង!!ហើយគេទៅហាត់សិល្បៈទៅហាត់អីគេគេ!!

កៈ ចាំ!!

ខៈ ហើយមីទូចនេះនៅទូចទេនេះនៅដេកជាមួយបងវា ការហើយវានៅណោះដេកជាមួយមីបងហ្នំ!!ស្រាប់តែមើលទៅជើងវាសុទ្ធតែផ្សូងហើយជើងវារយ៉ាស់រយាយមុតដែកគោលមែន!!ខ្ញុំខ្ញុំអស់អារម្មណ៍ហាំចង់ដួលលើកង់៣ញ៉ុមប្រាប់អូនឯងណាស់!!ដល់មកអូនអើយឃើញតែឆ្អឹងកំព្រឹងខ្លោចអស់រលីង!!

កៈ មកដល់ឃើញឈឺចាប់ណាស់មីង?

ខៈ ចាំ!!ខ្ញុំឃំអត់ចេញម៉ង ដឹងដឹងគិតយ៉ាងម៉េចញ៉ុមថាញ៉ុមចប់ហើយញ៉ុមមិនដឹងទៅនៅណានាំកូនទៅនៅឯណាទេ!!!ញ៉ុមគិតក្នុងចិត្តថាមានតែសុំបងប្អូនទេ ទិញបង់កៅស៊ូអោយកូននៅស្រាប់ដល់ហើយណោះណោះ ចិត្តគេធម៌អូនអើយ បងធម៌ញ៉ុមនៅរាល់ថ្ងៃហ្នឹងញ៉ុមរាប់គាត់ជាបងធម៌នៅកាវ៉ាស់សាំងហ្នឹងណាស់!!

កៈ ចាំ!!

ខៈ គ្រាន់តែស្អែកឡើងខ្ញុំទៅធ្វើការ គាត់អំពាវនាវថៅកែប្រេងហ្នឹង ថៅកែដឹកប្រេងអោយគាត់ហ្នឹងគ្រប់ថៅកែទាំងអស់ គាត់សុំគេអោយតែម្តងលុយណាស់!!

កៈ ចាំ!!

ខៈ ថាហ៊ីចុងភៅខ្ញុំភ្លើងឆេះផ្ទះអស់ហើយអោយសុំ១០រៀល២០រៀល គេអោយគ្រប់គ្នា!!

កៈ ចាំ!!

ខៈ មកណោះអ្នកណោះឮស្គរដំណឹងថាខ្ញុំភ្លើងឆេះផ្ទះគេផ្ញើ ផ្ញើលុយមកអាប្អូនញ៉ុមហ្នឹងវាប្រាប់ថាឥឡូវគេតែមកពីសាំងហ្គាពួរថាបងបាន៨០០ហើយ គេជួយបងឯងបាន៨០០ ស្អែកឡើងទិញឈើហើយ គ្រាន់តែគេអោយលុយមកខ្ញុំប្រគល់អោយទៅប្អូនគេអោយមកខ្ញុំប្រគល់អោយទៅប្អូន ធ្វើអីធ្វើទៅហ្អែង!!

កៈ ប្អូន?

ខៈ ប្អូនញ៉ុមជីដូនមួយ ធ្វើគ្រូបង្រៀន។

កៈ ចាំ!!

ខៈ ១២០០!!

កៈ ហ៊ីសំណាងហើយអ្នកមីងបានមានអ្នកជួយ។

ខៈ គេជួយមកអង្ករគ្រាន់តែមួយឆ្នាំស៊ីមិនទាន់អស់ផង!!អង្ករគ្រឿងគ្រៅមួយឆ្នាំអត់ចង់អស់ផងណាស់!!

កៈ ចាំ!!

ខៈ ខោអាវមក ដល់ពេលហើយវាទិញធ្វើផ្ទះធ្វើអីអោយហើយវាសល់ហ្នឹងវាទិញធុងទឹកវាទិញកន្ទេលវាទិញកាតូវាទិញស្អីៗអោយ ធុងចំពោះអាប្អូនញ៉ុមហ្នឹងហា!!

កៈ ចាំ!!

ខៈ ហើយខ្ញុំក៏អរគុណព្រះអង្គដែរ អាហ្នឹងតែយើងអធិស្ឋានសុំព្រះអង្គ!!

កៈ ចាំ!!

ខៈ ហើយអញ្ចឹងព្រះអង្គបំផ្លាញអាភាពអាក្រក់ហ្នឹងចោល!!

កៈ ហ្នឹងហើយ។

ខៈ ដាក់ភាពអោយល្អអោយយើងវិញ!!ហ្នឹងអញ្ចឹងអូនណាស់!!ខ្ញុំនឹងការអស្ចារ្យក្នុងជីវិតខ្ញុំកន្លែងហ្នឹងមួយស្តែងតែម្តង ថាឥឡូវថាប្អូនញ៉ុមទៅសិក្ខាសាលាណាទៅទៅញ៉ុមទៅដែរ !! ពេលមុនញ៉ុមអត់ចេះរាំទេនៅពីក្មេងអត់ដែលចេះរាំហ្នំ ចុះនៅពីក្មេងញ៉ុមអត់ដែលបានរាំណា!! ឥឡូវចាស់រាំដែរ!!

កៈ ចាំ!!

ខៈ ដើរលេងសប្បាយ!!

កៈ ហ្នឹងហើយសប្បាយតើមីងធ្វើអញ្ចឹង!!!

ខៈ ចាំ!!ឥឡូវញុំមលែងខ្វល់អីហើយព្រោះខ្ញុំធំៗអស់ហើយណាស់!!

កៈ ហ្នឹងហើយ!!!

ខៈ ញុំមរកបានប៉ុន្នានហូបប៉ុណ្ណឹងខ្ញុំត្រូវការសប្បាយ ខ្ញុំត្រូវការសប្បាយញុំមចាស់ញុំមត្រូវការសប្បាយ ខ្ញុំលែងខ្វល់ខ្វាយអីទៀតហើយ!!

កៈ ចាំ!!

ខៈ នោះបងខ្ញុំហ្នឹងក៏គាត់ជឿព្រះអង្គដែរ គាត់នៅឪវ៉ាល់គាត់មកនៅលេងប្អូននៅទីនេះ!!

កៈ ចាំហើយអរគុណច្រើនមីង ហើយមីងមានពាក្យអីចុងក្រោយដូចថាផ្តាំផ្ញើទៅកាន់កូនចៅមីងជំនាន់ក្រោយដែលគេបានស្តាប់ឮសំលេងមីងហ្នឹងអត់?

ខៈ ចាំញុំមមានពាក្យចង់ផ្តាំកូនៗទាំងអស់ដែលជំនាន់ក្រោយនេះ បើកូនជួបជីវិតដូចមីងក៏កូនពិបាកដែរ អឺចឹងសូមកូនធ្វើអ្វីអោយល្អត្រូវនឹងសង្គម កុំអោយសង្គមស្អប់ខ្ពើមព្រោះឥឡូវមុននឹងយើងធ្វើអ្វី!!

កៈ ចុះអ្នកមីងមានពាក្យអីចង់ផ្តាំទៅកូនមីងជំនាន់ក្រោយអីអត់មីង មានដូចថាចង់ផ្តាំផ្ញើរទៅកាន់កូនចៅមីងជំនាន់ក្រោយដែលបានស្តាប់ឮសំលេងរបស់មីងហ្នឹងហាំ?

ខៈ ចាំ សូមផ្តាំដល់កូនៗជំនាន់ក្រោយបើកូនបានស្តាប់សំលេងម្តាយហើយកូនត្រូវតែយកចិត្តទុកដាក់អោយដឹងថាអ្វីដែលម៉ែពិបាកអ្វីដែលម៉ែខំចិញ្ចឹមកូនអញ្ចឹងទៅណាស់អូនណាស់!!

កៈ ចាច៎!!

ខៈ ទៅកូនយកចិត្តទុកដាក់នៅក្នុងជីវិតរបស់កូនគ្រប់ៗគ្នាផងដែរ។

កៈ ចាំអញ្ចឹងអរគុណច្រើនមីងដែលបានផ្តល់អោយញុំមសំភាសន៍មីងនៅក្នុងថ្ងៃនេះហើយការសំភាសន៍នេះគឺបានបញ្ចូលនៅក្នុងវេបសាយរបស់សាលា ប៊ី វ៉ាយ យូ សហរដ្ឋអាមេរិចណាស់មីង!!

ក៖ ចាំចាំ!!បើសិនជាមីងចង់អោយកូនចៅមីងស្តាប់មីងអាចចូលស៊ើចចូលទៅក្នុងហ្នឹងទៅបាន
អោយពួកគាត់ស្តាប់សំលេងរបស់មីងបានចាំ អរគុណច្រើនមីងជំរាបលាមីង។